# សម្ភាសន៍ជាមួយៈ កែវ សារឹម ហៅ កែវ គុំ អាយុ៨៩ឆ្នាំ ភេទស្រី

មុខងារខ្មែរក្រហមៈ ដេរខោអាវ

មុខងារបច្ចុប្បន្នៈ ធ្វើស្រែចំការ

ស្រុកកំណើតនៅភូមិបន្ទីតាំងវែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ

រស់នៅភូមិតាសេកជ្រុំ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០១:៣១:៥០

៣២ទំព័រ

ដានី : អញ្ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

គុំ : ឈ្មោះ កែវ គុំ

ដានី : មីងអាយុប៉ុន្មានហើយសព្វថ្ងៃ?

គុំ : អាយុ ៨៩ឆ្នាំ

ដានី : ចុះមីងមានឈ្មោះតែមួយហ្នឹងទេ ឬក៏មានឈ្មោះមួយទៀត?

គុំ : ពីដើមម៉ោមានឈ្មោះឪពុកម្ដាយដាក់ឲ្យផ្សេង

ដានី : ឈ្មោះអីទៅ?

គុំ : ឈ្មោះ កែវ សារឹម ដំក្រោយមកយើងដូរពេលសម័យពាឆ្នាំ

ដានី : ឥឡូវប្រើតែ កែវ គុំទេ?

គុំ : ចា៎!ប្រើតែ កែវ គុំ

ដានី : ឈ្មោះ សារឹម គេអត់ស្គាល់ទេ?

គុំ : អត់ស្គាល់ទេនៅស្រុកម៉ាឡៃអត់ស្គាល់ទេសួររក សារឹម អត់មានអ្នកស្គាល់ដែរ

ដានី : បាទ!

គុំ : ព្រោះផ្លាស់តាំងពីឆ្នាំ៧៣នោះ

ដានី : ផ្លាស់ឈ្មោះតាំងពីឆ្នាំ៧៣ពេលដែលយើងចូលតទល់ធ្វើបដិវត្តន៍យើងផ្លាស់ម៉ោ?

គុំ : ចា៎!ចូលតស៊ូ

ដានី : ចុះឪពុកមីងគាត់ឈ្មោះអីដែរ?

គុំ ៖ ឈ្មោះ ហ៊ាង មិនដឹងស្អីហ៊ាងទេខ្ញុំភ្លេចហើយ

ដានី ៖ សព្វថ្ងៃនេះគាត់អាយុប៉ុន្មានហើយ?

គុំ ៖ ខ្ញុំអត់ដឹងទេ

ដានី ៖ គាត់នៅនៅឯណាឥឡូវ?

គុំ ៖ ឥឡូវគាត់នៅខ្វយ ម្ដាយខ្ញុំស្លាប់ហើយស្លាប់៧៩

ដានី ៖ ម្ដាយឈ្មោះអីទៅ?

គុំ ៖ ឈ្មោះ សំ

ដានី ៖ គាត់ស្លាប់នៅឆ្នាំ៧៩គាត់ស្លាប់ដោយសារមូលហេតុអី?

គុំ ៖ អត់ដឹងដែរព្រោះខ្ញុំបែកពីគាត់លីថាឈឺ

ដានី ៖ ឪពុកសព្វថ្ងៃនៅខ្វយ?

គុំ ៖ ចា៎!

ដានី ៖ ខ្វយហ្នឹងនៅក្នុងឃុំអីទៅ?

គុំ ៖ នៅឃុំអូរម្លូរ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

ដានី ៖ អញ្ចឹងស្រុកកំណើតមីងនៅឯណាទៅ?

គុំ ៖ នៅកំពង់ធំ នៅម៉ាដូរស្ទឹងជីនិត ស្រុកសន្ទុក ខេត្តកំពង់ធំ នៅឃុំបឹងល្វា ។

ដានី ៖ កំណើតនៅភូមិអីគេ?

គុំ ៖ ភូមិបន្ទីរតាំងវែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ

ដានី ៖ ជាប់កំពង់ចាមដែរ?

គុំ ៖ ចា៎!វាម្ខាងម្នាក់ជាប់ម្ខាងស្ទឹងម្នាក់

ដានី ៖ នៅខាងក្រោយភ្នំ?

គុំ ៖ ខ្ញុំនៅសន្ទុកដែរតែមកនៅជាប់ស្ទឹង

ដានី ៖ ចុះឪពុកម្ដាយមីងគាត់ផ្លាស់ទៅនៅខ្វយតាំងពីអន្កាល់?

គុំ ៖ កាលសម័យរត់៧៩ហ្នឹង

ដានី ៖ ចុះមីងមានបងប្អូនប៉ុន្មាននាក់ដែរ?

គុំ ៖ បងប្អូននៅស្រុកខ្ញុំចាំមិនបានទេ ចាំបានតែប្អូនៗខ្ញុំពីមុនម៉ោស្លាប់អស់ហើយនៅសល់តែពីរនាក់ តែក្រោយមកខ្ញុំចាំបានពីរនាក់ទៀត៤នាក់ប្រពន្ធចុងគាត់ទៀត

ដានី ៖ បាទ!

គុំ : បងប្អូនខ្ញុំបង្កើតមានបីនាក់ទាំងខ្ញុំហ្នឹងស្លាប់អស់ហើយមានច្រើនណាស់តែស្លាប់អស់នៅសល់តែបីនាក់ហ្នឹងឯង

ដានី : គាត់ស្លាប់ដោយសារមូលហេតុអី?

គុំ : អត់ដឹងដែរព្រោះខ្ញុំបែកម៉ោ

ដានី : ចុះអើពីរនាក់ទៀតបីនាក់ទាំងមីងពីរនាក់ទៀតនៅណា?

គុំ : នៅស្រុកជាមួយពុក

ដានី : នៅខ្ឈយអេស៎!?

គុំ : ចា៎!

ដានី : ពីរនាក់ទៀតស្រីឬប្រុស?

គុំ : ស្រីៗទាំងពីរ

ដានី : ប្អូនមីងឬក៏បងមីង?

គុំ : ប្អូនទាំងអស់ ហើយប្រពន្ធក្រោយទៀតពីរទៀតដែរតែខ្ញុំមិនសូវស្គាល់ ប៉ុនអាប្អូនៗខ្ញុំក្រោយក៏មិនសូវស្គាល់ខ្ញុំប៉ុន្មានព្រោះកាលខ្ញុំបែកហ្នឹងអាប្អូនខ្ញុំខ្លះកើតខ្លះមិនទាន់កើតទៀត

ដានី : ចុះប្អូនៗមីងបង្កើតគាត់ធ្វើអីដែលសព្វថ្ងៃហ្នឹង?

គុំ : ធ្វើស្រែធ្វើចំការហ្នឹង

ដានី : ចុះមីងធ្លាប់ជួបគាត់ប៉ុន្មានដងដែរតាំងពីបែក៧៩?

គុំ : ជួបគេមកលេងម្តង ប្អូនមួយទៀតគាត់មកលេងពីរដងម៉ោជាមួយពុក ប្អូនមួយទៀតបន្ទាប់ខ្ញុំមិនបន្ទាប់ទេតែដូចបន្ទាប់អញ្ចឹងព្រោះវាងាប់អស់អាហ្នឹងមកលេងតែម្តងគត់

ដានី : ឈ្មោះអីខ្លះ?

គុំ : ឈ្មោះ ភី ដា

ដានី : ចុះមីងអ្នកភូមិនេះគេហៅភូមិអីគេដែរ?

គុំ : ភូមិនេះ?

ដានី : បាទ!

គុំ : ភូមិតាសេដ្រ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ដានី : ចុះគ្រួសារមីងគាត់ឈ្មោះអីដែរ?

គុំ : ឈ្មោះ ស៊ូ ឈិន

ដានី : សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ?

គុំ : គាត់អាយុ៥៣

ដានី ៖ គាត់ធ្វើអីដែរឥឡូវ?

គុំ ៖ គាត់ធ្វើប្រជាជនធម្មតា

ដានី ៖ ប្រជាជនតែអត់ធ្វើស្រែចំការទេ?

គុំ ៖ មុខរបរធ្វើស្រែចំការ បើអត់ធ្វើចំការធ្វើស្រែហើយនឹងចិញ្ចឹមមាន់ ទា តិចតួចហ្នឹង

ដានី ៖ ចុះមីងមានកូនចៅប៉ុន្មាននាក់?

គុំ ៖ ខ្ញុំមានកូន៤

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

គុំ ៖ ស្រី២ ប្រុស២

ដានី ៖ សព្វថ្ងៃគាត់ធំៗអស់ហើយ?

គុំ ៖ ធំហើយពៅគេអាយុ១២-១៣ហើយ

ដានី ៖ ចុះបង?

គុំ ៖ បងគេមិនអាយុហើយទេឆ្នាំឆ្លូវ ឆ្នាំ៨៥

ដានី ៖ បាទ!អាយុ២៦ហើយ?

គុំ ៖ ចាំ!

ដានី ៖ គាត់ធ្វើអីដែរសព្វថ្ងៃកូន?

គុំ ៖ ដូចខ្ញុំថាអញ្ចឹងទៅធ្វើកម្មករនៅថៃស្រុកថៃអស់ហើយធ្វើខាងសំណង់

ដានី ៖ កូនមីងមានគ្រួសារប៉ុន្មាននាក់ហើយ?

គុំ ៖ ២នាក់ហើយ

ដានី ៖ ចុះមីងកាលបែកឆ្នាំ៧៩ម៉ោមីងទៅនៅឯណាខ្លះទៅ

គុំ ៖ ម៉ោនៅហ្នឹង៧៩រត់បែកពីភ្នំពេញម៉ោខ្ញុំមកនៅត្រាងអូរម្លូរមកនៅហ្នឹងបានប៉ុន្មានខែបានមកនៅ នេះ៧៩ខែ១០-ខែ១១បានខ្ញុំមកនៅភូមិដូងរហូតដល់សព្វថ្ងៃហ្នឹង

ដានី ៖ ដំបូងនៅភ្នំពេញរត់ម៉ោនៅត្រាងអូរម្លូរហើយបានម៉ោនៅភូមិដូងម៉ាឡែ

គុំ ៖ ចាំ!

ដានី ៖ កាលហ្នឹងម៉េចបានមីងរត់មកនៅហ្នឹង?

គុំ ៖ កាលហ្នឹងខ្ញុំនៅត្រាងដល់ពេលគេគុំរូវឲ្យមកនៅដឹកជញ្ជូននៅនេះ កាលមុនខ្ញុំនៅស្នាក់ការនៅ ត្រាងដល់ពេលនេះគេយកមកនៅនេះ

ដានី ៖ មីងអាចជួយរៀបរាប់ប្រាប់ខ្ញុំពីដំណើរដូចថាកាលពីម៉ោពីភ្នំពេញមកនៅហ្នឹងមូលហេតុអីបានមីង មកនៅត្រាង?

គុំ ៖ មូលហេតុដំបូងខ្ញុំរត់ៗយួនហ្នឹងម៉ោហ្នឹងឯង

ដានី ៖ យួនចូលកាលពី៧៩ហ្នឹង?

គុំ ៖ កាលមុននៅពេញខ្ញុំនៅបុរីកីឡា ដល់ពេល ៧ មករា ខ្ញុំរត់ម៉ោរត់ចេះរត់ៗម៉ោជួបទ័ពស្គាល់គ្នាចេះតែម៉ោតាមគ្នាម៉ោនៅត្រាងព្រោះដឹកនាំយើងស្គាល់អ្នកដឹកនាំហ្នឹងនៅត្រាងហ្នឹងម៉ោនៅត្រាងជាមួយគ្នាម៉ោ ។

ដានី ៖ នៅត្រាងនៅធ្វើអីទៅ?

គុំ ៖ នៅស្នាក់ការគេហៅនៅស្នាក់ការ ។

ដានី ៖ នៅក្នុងស្រុកម៉ាខ្មែរដែរអត់អូរម្លូរ?

គុំ ៖ អត់ទេ!នៅខាងនោះផ្សេង ខាងសំពៅលូនអី ខ្ញុំមិនសូវដឹងផងឥឡូវនៅខាងប៉ៃលិនជិតប៉ៃលិនពីសាលាក្រៅម៉ោត្រាងហ្នឹងហើយបានអូរម្លូរបានម៉ោសាសស្តារម៉ោខ្សែននេះ ។

ដានី ៖ អ្ហូ!ជលៀរហ្នឹងដែរ?

គុំ ៖ ចា៎!មិនមែនស្រុកម៉ាខ្មែរទេ ។

ដានី ៖ កាលគ្នាច្រើនទេមីងកាលជំនាន់៧៩ម៉ោ?

គុំ ៖ គ្នាច្រើនដែរណ្ហឹង ដូចថាគេរើសម៉ោម៉ាកងអញ្ចឹងទៅម៉ោនៅត្រាងហ្នឹងនៅគ្នាច្រើនច្របូកច្របល់មិនដឹងពីណាពីណីខ្ញុំមិនស្គាល់គេដែរ ប៉ុនយើងស្គាល់គ្នាម៉ាអ្នកនៅអគ្គភាពជាមួយគ្នាពីភ្នំពេញម៉ោហើយនឹងស្គាល់អ្នកដឹកនាំពីពេញម៉ោ បានមកជុំគ្នាត្រាងដល់ពេលនៅហ្នឹងបានប៉ុន្មានខែទេកាលហ្នឹងអត់បាយអត់មានបាយ អត់មានអីហូបទេកាលហ្នឹង យួនវាបុកចូលដល់ព្រំដែនថៃ អត់មានបាយបានគេរើសមកនៅធ្វើដឹកជញ្ជូននៅភូមិដូនវិញ រើសម៉ោគ្នាច្រើនដែរហ្នឹងជាប់គ្នា៣០-៤០នាក់ដែរហ្នឹងម៉ោនៅរហូតតាំងពីចុង៧៩មករហូតទល់ឥឡូវហ្នឹង ។

ដានី ៖ បាទ!

គុំ ៖ ម៉ោនៅហ្នឹងដឹកជញ្ជូនរហូតទឹម៨៥ហ្នឹងខ្ញុំរត់ មុន៨៥ខ្ញុំមានគ្រួសារហ្នឹងបានទៅនៅដីថៃហ្នឹងបែកម៉ាខ្សែទៅនៅដីថៃដល់ពេល៩០នេះបានវិវត្តន៍ម៉ោនៅព្រំដែនវិញ ។

ដានី ៖ ចុះមីងកាល៧៩មីងរត់ម៉ោមានចំរុះគ្នាច្រើន ប៉ុន្តែដូចថាមីងម៉ោគ្នាម៉ាកងពីបុរីកីឡា?

គុំ ៖ ចា៎!គ្នាម៉ាក្រុមមានកូនក្មេងច្រើនណាស់ប៉ុនបែកគ្នាអស់ហើយម៉ោធ្វើរនឹងសហករណ៍ក្មេងៗតូចៗហ្នឹងម៉ោធ្វើរតាមសហករណ៍ខ្លះទៅជួបម៉ែឪគេ គេចូលទៅអ្នកអត់ចេះតែម៉ោៗទាំងក្មេងទាំងអ្នកធំៗអញ្ចឹងរហូតម៉ោនៅត្រាងហ្នឹង

ដានី ៖ បាទ!

គុំ ៖ មុនដំបូងមកនៅស្នាក់ការនៅកំរៀង ដល់ពេលកំរៀងហ្នឹងគេរំបែកកំរៀង បែកទៀតម៉ោនៅត្រាង ។

ដានី ៖ មកនៅត្រាង?

គុំ ៖ ចា៎!មកនៅត្រាង ដល់ពេលនេះមកនៅដីថៃ ដល់ពេលនេះគេរើសមកនៅហ្នឹងប្រដោយទៅ ។

ដានី ៖ កាលហ្នឹងពីណាគេអ្នកដឹកនាំដូចថាយើងអ្នក...?

គុំ ៖ អ្នកដឹកនាំម៉ោខ្ញុំភ្លេចអស់ហើយ ហើយអ្នករើសឈ្មោះម៉ោឥឡូវគាត់ស្លាប់អស់ហើយ ពូទង់នៅខាង៣២ គាត់ឲ្យម៉ោ ពូដន ពូអ៊ីហ្នឹងគាត់រើសឈ្មោះពួកខ្ញុំម៉ោ ។

ដានី ៖ ចុះមីងកាលពីយើងរត់ម៉ោដំបូងកាលពី៧៩ ម៉ោយ៉ាងម៉េចដែរ?

គុំ ៖ រត់តាមផ្លូវ?

ដានី ៖ បាទ!នៅតាមផ្លូវ?

គុំ ៖ តាមផ្លូវរត់ៗរហូតហ្នឹង និយាយទៅដើរតាំងពីពេញម៉ោរហូត ដើរម៉ោដល់ខ្ញុំមកដល់គេហៅត្រពាំង ជរអមលាំងហ្នឹង គេឲ្យនៅស្នាក់ហ្នឹងគេថាកម្មករមកពីពេញគេឲ្យស្នាក់ហ្នឹងសិន ។ ទៅកាប់ចំការជា មួយប្រជាជនហ្នឹង ទៅកាប់ចំការបានហើយប្រជាជនចេះតែខបត្តមអង្ករឲ្យហូប ហើយយើងទៅធ្វើ ការជាមួយប្រជាជន ទៅដល់ពេលនេះគេប្រកាសថាអ្នកមកពីពេញ អ្នកកម្មករឲ្យមកលិចហ្នឹងអស់ សំដៅឲ្យមកម៉ក់ហឿន គេថាទៅម៉ក់ហឿនទៅបន្ទិលហ្នឹង គេសំបូរស្រូវឲ្យមកជួយប្រមូលផលនៅ ហ្នឹងហើយនាំគ្នាម៉ោកាត់ព្រៃកាត់ផ្សែអត់បាយអត់ទឹក ចេះតែម៉ោៗមកដល់កន្លែងត្រង់ណាមួយ នោះគេហៅពួកខ្ញុំហ្នឹង ទៅនៅមួយឡែកគេសួរថានៅត្រង់ណាៗអញ្ចឹង គេហៅទៅនៅមួយឡែកដឹ ទៅនៅគេរៀបចំប្រុងថានឹងយក ទៅកន្លែងគេហៅថាព្រៃកដីកៗ ម៉ោស្រុកបាកានមកដល់ហ្នឹងគេ ឃាត់ទុកមកដល់កន្លែងហ្នឹង យប់ឡើងប្រជាជនថាកុំចុះដីឲ្យសោះណាក្មួយ ហើយគាត់ថាបើគេ និយាយអីមិនបាច់តគេទេឲ្យគេថាអីថាទៅយើងនៅឲ្យស្ងៀមខ្លាចគេសម្លាប់ ដល់ហើយអ្នក ប្រធានសហករណ៍ហ្នឹង គេបញ្ជាឲ្យពួកខ្ញុំនឹងថា ស្អែកកាប់រណ្តៅ៣នាក់រណ្តៅមួយមិនទាន់បាន ស្អែកដងអ៊ីដូចថាដែលប្រជុំថ្ងៃនេះអញ្ចឹងទៅធ្វើការជាមួយប្រជាជនហ្នឹង ត្រឡប់មកវិញឃើញ ទ័ពយើងមកទ័ពអ្នកដែលស្គាល់គ្នានិយាយឲ្យចំទ័ពតាដៀមហ្នឹង ។

ដានី ៖ បាទ!ទាហានខាង....?

គុំ ៖ ចា៎!ទាហានខាងខ្មែរក្រហមហ្នឹង ម៉ោដល់ហ្នឹងក៏ប្រមូលពួកខ្ញុំអស់ក៏ទៅយកពីអ្នកទៅព្រៃកដីកគេបំបែកគ្នាៗពួកខ្ញុំតែ១៥នាក់ទេប៉ុនគេបំបែកអត់ឲ្យនៅជាមួយគ្នាទេដល់ហើយទៅប្រមូលអស់ដល់ហើយប្រជាជនទៅនិយាយប្រាប់ថាក្មួយអើយគេនិយាយអីមិនបាច់តទេព្រោះអីនោះហើយ

កុំរត់ឲ្យសោះគារត់ខ្លាចគេបាញ់សាប់គាត់ប្រាប់ប្រជាជនគាត់ស្រលាញ់យើងដែលនោះ ។គាត់ថាក្មួយអើយកុំរត់កុំអីគារត់គេបាញ់សាប់ហើយអត់រស់ទេនោះគេចាប់ម្នាក់ដែលខាងពួកកាត់ដេរត់នារីខាងកាត់ដេរត់ៗ ហើយគេចាប់វៃហើយក្មួយឯងកុំរត់នឹងគេណាស់ក្មួយណាស់

ដានីៈ ពីណាគេអ្នកវៃ

គុំៈ ប្រជាជនប្រធានសហករណ៍ហ្នឹងខ្ញុំមិនស្គាល់ដែរ

ដានីៈ ប្រធានសហករណ៍ខាងខ្មែរក្រហមហ្នឹង?

គុំៈ អត់ទេ!អ៊ីមែនប្រធានសហករណ៍ខ្មែរក្រហមហ្នឹងៗ

ដានីៈ បាទ!

គុំៈ ប្រធានសហករណ៍ខ្មែរក្រហមហ្នឹង ថាក្មួយឯងនិយាយអីចាស់ជាមួយគេអត់បានទេគេថាឲ្យនៅៗ គេថាឲ្យរត់ៗប៉ុនគេមិនឲ្យយើងរត់ទេមិនដឹងគេដែនការណ៍ប្រុងយ៉ាងម៉េចទេដែលប្រុងសម្លិសពួកខ្ញុំចោលនឹងឯងមើលទៅចេះទ័ពពួកយើងម៉ោទាន់ដល់ម៉ោទាន់..

ដានីៈ ទ័ពមកពីខាងណា?

គុំៈ ទ័ពពួកខ្មែរក្រហមហ្នឹងឯង

ដានីៈ បាទ!ប៉ុន្តែទ័ពមកជួយមកពីខាងណា?

គុំៈ ពីភ្នំពេញម៉ោ ពួកអ្នកវៃខាងយោធា ខាងក្រសួងខាងមន្ទីរនៅជុំគ្នាហ្នឹង ខាងយោធា១៨៧០ ហ្នឹងជួបម៉ោប្រមូលទៅ រួចហើយអ្នកដែលប្រុងធ្វើបាបគេហ្នឹង គ្រាន់តែទ័ពមកដល់ជិះសេះរត់បាត់ អត់ហាននៅទេខ្លាច ហើយប្រជាជនគ្រាន់ចេញម៉ោពីភូមិហ្នឹង ម៉ោដល់គេហៅកោះក្រឡហ្នឹង អត់មានប្រជាជនទេ រត់អស់ប្រជាជន តែខ្ញុំអត់ដឹងមូលហេតុអីដែរ ។

ដានី ៈ ចុះមីងកាលហ្នឹងកាលមីងរត់មកដល់កន្លែងអ៊ីអមលាំងអ្នកដែលថាឲ្យម៉ោខាងលិច....?

គុំ ៈ ហ្នឹងដូចថាគេប្រកាសដូចថា មិនដឹងជាអ្នកណាៗ លឺតៗគ្នាពីក្រសួងមួយ ទៅក្រសួងមួយ ហ្នឹងណាស់ដូចវាមាននៅចំរុះ មានពួកខ្ញុំអញ្ជើងខាងក្រសួងមន្ទីរអញ្ជើងទៅ មានខាងសាធារណៈកាលដឹកជញ្ជូនដូវគោក មាននៅជុំគ្នាទេ ដូចថានៅទាំងអស់គ្នាឃើញគ្នាស្គាល់ គ្នារាល់ថ្ងៃហ្នឹងមិនដឹងលឺពីណាទេ កាលហ្នឹងតាមការពិតខ្ញុំថាទំនោងបែបតាម៉ុកហើយមើលទៅ ។

ដានី ៈ តាម៉ុក?

គុំ ៈ ចាំ!អាចតាម៉ុក ហើយអ្នកដឹកនាំទាំងអស់ហ្នឹងប្រកាសឲ្យហ្នឹងហើយបានម៉ោ ម៉ោហ្នឹងគេចែកអង្ករ ឲ្យស្នាក់ៗៗតាមដូវ ម៉ោដល់គេហៅភូមិព្រែកដឹកហ្នឹង ដាច់រយៈហើយពួកខ្ញុំដាច់រយៈគេហៅ ទុកម៉ាដុបដែលខ្ញុំនិយាយថានៅ ។

ដានី ៈ ចុះព្រែកដឹកនៅណា?

គុំ : ព្រែកជីកនៅខាងស្អីខ្ញុំមិនស្គាល់ទេ ខាងសំឡូតខាងកោះក្រឡមិនដឹងស្រុកស្អីៗ ខ្ញុំមិនដឹងដែរ

ដានី : បាទ!ៗ ហើយម៉េចទៀតទៅ?

គុំ : ដល់ពេលនេះបន្ទាប់ម៉ោក៏នាំម៉ោ ជាមួយទ័ពរហូតម៉ោ នៅធ្វើស្នាក់ការនៅវ៉ៃនៅកំរៀងហ្នឹង បណ្ដោទៅ បានរួចម៉ោរហូតហ្នឹងតែមុននឹងមកដល់កំរៀងហ្នឹង ឡើងភ្នំកន្ទះខែ ។

ដានី : អ្ហូ!ឡើងយ៉ាងម៉េចទៅ?

គុំ : ឡើងពីភ្នំគេហៅភ្នំសាលាស្រុកអាឈូនហ្នឹង ឡើងតាំងពីហ្នឹង ម៉ោរហូតដល់ភ្នំខៀវ តាមព្រំដែន មិនដឹង ខាងណាៗ ខាងណាខាងណីទេចេះតែដើរតាមគ្នា នឹងទៅមានទៅជួបអ្នកពិការអ្នករបួស តាមផ្លូវ ហើយគេចេះតែម៉ោទៅខ្លះអូសគោអូស អីវ៉ៃហូបតាមផ្លូវរហូតចេះតែចេញម៉ោ ចុះនឹងគេហៅ បរតាំងសួរចុះភ្នំណ្ហឹងឯងខ្ញុំចុះម៉ោៗជួបនឹងកងទ័ពវៀតណាម នៅហ្នឹងទៀត នាំគ្នារត់ម៉ោចូលដីថៃ អត់ស្គាល់ថៃសោះកាលហ្នឹងខ្ញុំម៉ោថៃគេដឹកម៉ោនៅកំរៀង ។

ដានី : ចូលដីថៃៗដឹកម៉ោនៅកំរៀងវិញ?

គុំ : ចា៎!កាលហ្នឹងអ្នកដឹកនាំគេតាមជាប់ដែរហ្នឹងតាមទាក់ទងដូចថា!

ដានី : មេដឹកនាំឈ្មោះអីទៅកាលហ្នឹងកាលហ្នឹង?

គុំ : កាលហ្នឹងពូហុងពូអីហ្នឹង ។

ដានី : ពូហុងណា? ឥឡូវគាត់នៅឯណាពូហុង?

គុំ : ឥឡូវអត់ដឹងគាត់នៅឯណា គាត់នៅខ្ញុំអត់ដែលឃើញមុខគាត់ផង ឃើញម្ដងៗផ្ទះគាត់នៅនេះ ក៏មាន ។

ដានី : នៅម៉ាឡៃហ្នឹង?

គុំ : ចា៎!

ដានី : ហុងកាលមុនកាលសម័យពន្ធនាំនៅក្រសួងការបរទេសឬក៏នៅក្រសួងពាណិជ្ជកម្ម?

គុំ : ចា៎!នៅក្រសួងការបរទេស គាត់ចេះតែទាក់ទងទៅថៃថាបើឃើញយើងជនភៀសខ្លួនឲ្យទទួលអី ផងទាក់ទងជាមួយទ័ពបានចេះចូលជាមួយថៃ ចេះដឹកនាំម៉ោៗ នៅកំរៀងៗ បាននៅស្នាក់ការ កាល ចុះពីភ្នំម៉ោអត់ស្គាល់សោះហើយគេថាដល់ថៃ ហើយខ្ញុំថាថៃមុខយ៉ាងម៉េចទៅមុខ ដូចខ្មែរយើងដែរ ។

ដានី : បាទ!ចុះមីងអ៊ើពូហុងផ្ទះគាត់នៅហ្នឹងគាត់មានដែលមកលេងហ្នឹងដែលឬអត់?

គុំ : ឥឡូវហ្នឹងគាត់នៅគាត់ធ្វើចំការ ធ្វើអីនៅធ្វើចំការនៅថ្មបាំងនៅឯនោះ ។

ដានី : ប៉ុន្តែនៅម៉ាឡៃនេះគាត់នៅដែរ?

គុំ : គាត់នៅប្រពន្ធគាត់នៅម៉ាឡៃហ្នឹងឯង ។

ដានី ៖ ផ្ទះគាត់នៅម្តុំណា?

គុំ ៖ នៅកន្លែងផ្សារតាំងពីមុនម៉ោនៅម្តុំហ្នឹងឯង

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី?

គុំ ៖ ឈ្មោះមីងឈឿន

ដានី ៖ ប្រពន្ធគាត់នៅធ្វើអីធ្វើចំការ?

គុំ ៖ ធ្វើចំការធ្វើស្រែដូចតែយើងដែររហូត

ដានី ៖ ប៉ុន្តែពូហុងគាត់នៅធ្វើចំការនៅថ្មបារ?

គុំ ៖ គាត់ទៅធ្វើទាំងអស់គ្នាហ្នឹងទៅម៉ោៗផ្ទះគាត់នេះដែរហ្នឹង ។

ដានី ៖ ចុះមីងកាលហ្នឹងដូចការរត់អីនោះមានជួបការលំបាកយ៉ាងម៉េចខ្លះ?

គុំ ៖ ពិបាកមិនបាច់និយាយទេសល់ពីនោះ មកដល់នេះដូចអាយុមិនអស់ដូចអាយុវែងម៉ងកាលហ្នឹងឡើងភ្នំតែឈើគេយកមកមិនរួចទេ គេចោលនៅហ្នឹងហើយប៉ុនកាលហ្នឹងពួកខ្ញុំមិនសូវមានអ្នកណាឈឺទេចោលទេមានតែអ្នកពិការ ។

ដានី ៖ អញ្ចឹងតែឈឺគេចោលហើយ?

គុំ ៖ ចាំ! វែឈឺគេចោលហើយតែឈឺគេយកមកម៉េចរួចប៉ុនអត់មានអ្នកឈឺដែរម៉ោក្រុមខ្ញុំដែលដើរហ្នឹងដើរម៉ោជាមួយគ្នាវាមានក្រុមផ្សេងៗគ្នាមិនដឹងខាងណាខាងណីអត់ដឹងទេ ។

ដានី ៖ ហ្នឹងសុទ្ធតែនៅក្នុងឆ្នាំ៧៩ទាំងអស់?

គុំ ៖ ចាំ! ៧៩ហ្នឹង

ដានី ៖ ចុះមីងមួយទៀតខ្ញុំស្តាប់លឺមីងថាភ្នំអីភ្នំសាលាឈ្លូនម៉េច?

គុំ ៖ សាលាស្រុកខឈ្លូនហ្នឹង?

ដានី ៖ សាលាស្រុកខឈ្លូនហ្នឹងអីគេ?

គុំ ៖ សាលាស្រុកហ្នឹងកាលពីសម័យហ្នឹងគេហៅសាលាស្រុកៗហ្នឹង ឡើងពីសំឡូតម៉ោហ្នឹងហើយឡើងភ្នំម៉ាជួរភ្នំខៀវមិនដឹងភ្នំអីៗខ្លះ ខ្ញុំអត់ស្គាល់ឡើងកន្លះខែគត់បានមកដល់ ។

ដានី ៖ អញ្ចឹងសាលាស្រុកខឈ្លូននៅភ្នំដែរ?

គុំ ៖ អត់ទេនៅក្រោមតែម្តាលពីឆ្លងកាត់ម៉ោ រត់តាមម៉ោហ្នឹងម៉ោពីភ្នំពេញចេះតែម៉ោដំណាក់ៗម៉ោជា មួយទ័ពមកដល់មកនៅជាមួយទ័ព ទ័ពហ្នឹងវ៉ៃភ្នំសំពៅ ដល់ពេលគ្រាប់ផ្លោងគ្រាប់អីម៉ោៗទប់ជិត ម៉ោពួកខ្ញុំហ្នឹងរត់ឡើងភ្នំម៉ោ តាមដែលគេហៅសាលាស្រុកខឈ្លូនហ្នឹងឡើងភ្នំតាមហ្នឹងម៉ោរហូត មិនដឹងជាត្រង់ណាត្រង់ណីតាំងពីឡើងភ្នំសាលាស្រុក ម៉ោរហូតអត់ដែលឃើញវាលទេឃើញតែ ព្រៃភ្នំហើយអង្គរស្ពាយម្នាក់ម៉ាតៅៗទុកបបរហូបតាមផ្លូវចុះភ្នំឡើងភ្នំ ។

ដានី ៖ ដល់ពេលចុះមកពីភ្នំខៀវមកជួបនឹងកងទ័ពវៀតណាមរត់ចូលទៅណាវិញ?

គុំ ៖ រត់មកនៅព្រំដែនហ្នឹងអ្នកដឹកនាំយើងទាក់ទងទៅថៃៗដឹក ដឹកគ្រាន់តែពីគេហៅសាលាក្រោមក នៅត្រាំងនេះដដែលហ្នឹង ចូលមកស្អីគេហៅឡែនដឹកមកឡែនហ្នឹង ។

ដានី ៖ កាលហ្នឹងថ្នាក់ដឹកនាំមានអ្នកណាខ្លះ?

គុំ ៖ ខ្ញុំមិនសូវស្គាល់ខ្លះដែលហ្នឹង និយាយឲ្យចំទៅឲ្យតែនៅក្រសួងការបរទេសអ្នកដឹកនាំហើយអ្នកដឹកនាំការបរទេសហ្នឹង ។

ដានី ៖ អៀង សារី ហ្នឹង?

គុំ ៖ ចាំ!អ៊ំអៀង សារី អ៊ំហុង ប្រពន្ធគាត់អ៊ីហ្នឹង ។

ដានី ៖ ប្រពន្ធអៀង សារី ឈ្មោះអៀង ធីរិទ្ធអេស់?

គុំ ៖ ចាំ!គាត់ហ្នឹងឯងអ្នកដឹកនាំទាក់ទងសំខាន់ គាត់ទាក់ទងខាងបរទេសឲ្យពេលយើងចូលទៅអត់មានបញ្ហាអីទេ រឿងកាប់សម្លាប់អីអត់ទេប៉ុនវាំនៅមានខ្លះហើយអ្នកអាក្រក់នោះ ដូចតែយើងខ្មែរដែរថៃប៉ុនខ្ញុំចូលទៅខ្ញុំអត់មានជួបប្រទះថៃធ្វើបាបអីទេកាលហ្នឹង ។

ដានី ៖ ចុះបន្ទាប់មកមីងមកនៅត្រាងយ៉ាងម្តេចទៀតទៅ? មកនៅកំរៀងដូចថាការរស់នៅ?

គុំ ៖ ការរស់នៅកាលហ្នឹងអត់មានអីហូបទេ តែយើងទាក់ទងគណៈដឹកនាំយើងហ្នឹងទាក់ទងបើកអង្ករឲ្យគ្រាន់តែរស់ៗមិនបានច្រើនក៏បានតែរស់ៗម៉ាអាទិត្យបើកឲ្យម្តងអញ្ចឹងទៅ ម៉ាអាទិត្យគេឲ្យដូចថាមួយថ្ងៃពីរបុមួយកំប៉ុងអញ្ចឹងទៅថ្ងៃគេឲ្យមួយកំប៉ុងអញ្ចឹងទៅតាមដូចថាពេលដឹកបានយកម៉ោទៅថៃគេដឹកយកមកឲ្យទៅយើងចែកហូបទៅចែកទៅទ័ពទៅចុះទ័ពច្រើននោះវាមិនតែម៉ាក្រសួងទេណាវាមានច្រើនផ្នែកអ្នកភៀសខ្លួនមកទាំងអស់ហ្នឹងចេះតែចែកទៅ ។

ដានី ៖ កាលហ្នឹងមីងអាយុប៉ុន្មានកាលឆ្នាំ៧៩?

គុំ ៖ ខ្ញុំអាយុ១៨-១៩ប្រហែល១៨

ដានី ៖ បាទ!ដល់មកដល់ហ្នឹងមីងធ្វើអីទៅ? មកដល់ត្រាងមកដល់កំរៀងហ្នឹង?

គុំ ៖ ពេលមកដល់ត្រាងខ្ញុំធ្វើជាអ្នកស្នាក់ ការចាំសែងអ្នករបួសដូចថា ពេលមានអ្នករបួសគេទៅមុខរបួសម៉ោសែងមកពេទ្យអញ្ចឹងទៅ ។

ដានី ៖ គ្រាន់តែអ្នកសែងទេមិនអ្នកព្យាបាលមិនពេទ្យធ្វើព្យាបាលទេ?

គុំ ៖ អត់ទេខ្ញុំអត់មានពេទ្យព្យាបាលទេ គ្រាន់តែអ្នកសែងអ្នករបួសពីមុខគេវ៉ៃម៉ោពីមុខយើងសែងម៉ោដាក់ពេទ្យ ។

ដានី ៖ បាទ!រយៈពេលប៉ុន្មានទៅពេលដែលសែងហ្នឹង?

គុំ ៖ ខ្ញុំមិនចាំដែលរយៈពេលមួយខែពីរខែខ្ញុំមិនសូវចាំទេ

ដានី ៖ ហើយបន្ទាប់ពីហ្នឹងម៉ោធ្វើអ៊ីទៀត?

គុំ ៖ បន្ទាប់ពីហ្នឹងម៉ោរត់ម៉ោមកនៅត្រាងហ្នឹង ដូចថា ទ័ពឥតទៅមុខបញ្ជូនគ្រាប់ដូចថាជញ្ជូនពីកំរៀងហ្នឹងតាមផ្លូវដីថៃពីកំរៀងមកដាក់ត្រាងហ្នឹងទៅតាមដីថៃនៅដឹកជញ្ជូនដដែល ។

ដានី ៖ ដឹកជញ្ជូនអ្នកត្រូវរបួសខាងកងទ័ព ហ្នឹងគេហៅថាអ្នកដឹកជញ្ជូន?

គុំ ៖ ចា៎!

ដានី ៖ អ្នកណាគេជាអ្នកគ្រប់គ្រងនៅកន្លែងដឹកជញ្ជូន?

គុំ ៖ ខ្ញុំភ្លេចអស់ហើយ

ដានី ៖ ដូចថាយើងអ្នកដឹកជញ្ជូនខាងអ្នកត្រូវរបួស?

គុំ ៖ ជញ្ជូនអ្នករបួសដូចថា ត្រូវទៅយកគ្រាប់ទៅយកគ្រាប់ម៉ោបើអ្នកឈឺទៅមិនរួចទៅនៅកន្លែងហ្នឹងទៅ ។

ដានី ៖ យ៉ាងម៉េចទៀតទៅ?

គុំ ៖ ចេញពីហ្នឹងម៉ោមកនៅភូមិដូងមកនៅដឹកជញ្ជូនដែរ

ដានី ៖ អ៊ូ!ភូមិដូងមកនៅឆ្នាំណា?

គុំ ៖ មកនៅចុងឆ្នាំ៧៩ហ្នឹងដែរ ។

ដានី ៖ មកនៅភូមិដូងគេជ្រើសរើសម៉េចបានមកនៅភូមិដូង?

គុំ ៖ អត់ជ្រើសរើសខ្ញុំអត់ដឹងដែរតែគ្រាន់ថា អ្នកធ្លាប់នៅកន្លែងក្រសួងការបរទេសហើយកន្លែងពួកខ្ញុំនៅ៨៧០ហ្នឹងគេរើសម៉ោ ខទាហរណ៍ដូចថាពូឯងអ្នកដឹកនាំអ្នកស្គាល់គ្នាអ្នកគ្រប់គ្រងពីមុនម៉ោអញ្ចឹងថាត្រូវទៅនោះ ទៅមកនៅភូមិដូងនេះម៉ោមិនបាច់ឲ្យទៅណាទេកាលហ្នឹងគេប្រកាសថាអ្នកឲ្យណាចង់ទៅស្រុកទៅៗអញ្ចឹង ដល់ពួកខ្ញុំមិនដឹងទៅណាទេមិនដឹងស្រុកចេញពីស្រុកយូរណាស់ហើយទៅស្រុកឯណា ដល់ហើយគាត់ថាមិនបាច់ទៅណាទេឲ្យមកនៅនេះម៉ោ ។

ដានី ៖ កាលដំបូងកាលចុងឆ្នាំ៧៩នៅភូមិដូងមានមនុស្សច្រើនទេ?

គុំ ៖ មនុស្សច្រើនដែរតែសុទ្ធតែនារីដឹកជញ្ជូនហើយនឹងកងទ័ពអត់មានប្រជាជនទេ ប្រជាជនអត់មានទេមានតែអ្នកមកពីភ្នំពេញម៉ោមានកូនមួយ ពីរអញ្ចឹង ។

ដានី ៖ អញ្ចឹងសុទ្ធតែពួកធ្លាប់នៅក្រសួងការបរទេសនឹងនៅមន្ទីរ៨៧០?

គុំ ៖ ចា៎!ហើយអ្នកដែលចល័តនេះដែរ ។

ដានី ៖ ចល័តណា?

គុំ ៖ ចល័តនិមិត្តនេះដែរចល័តនិយាយរួមមិនដឹងចល័តណាណីខ្លះទេ មកនៅជុំវិញហ្នឹងទាំងអស់

ដានី ៖ យ៉ាងម៉េចទៅការរស់នៅក្នុងភូមិដូងពេលហ្នឹងយ៉ាងម៉េចទៅ?

គុំ ៖ កាលហ្នឹងដែងអ្នកដឹកនាំយើងទាក់ទងដូចជា អង្ករដូចជាម្ហូបអីម៉ោហើយដឹកជញ្ជូនយកទៅឲ្យទ័ព ប៉ុនមិនដឹងទាក់ទងមកពីណាពីណីខ្ញុំមិនសូវដឹងដែរ ។

ដានី ៖ តែហូបចុកគ្រប់គ្រាន់ទេកាលហ្នឹង?

គុំ ៖ ហូបចុកកាលដំបូងមិនសូវគ្រាប់គ្រាន់ប៉ុន្មានទេប៉ុនដូចថា ទ័ពអញ្ចឹងដឹកជញ្ជូនយកទៅមិនទាន់ក៏ខ្វះខាតដែរដំក្រោយម៉ោ ទើបមានកាកបាទក្រហមចូលៗមិនដឹងជាឆ្នាំណាទេខ្ញុំភ្លេចដែរទំនោរដូចជា៨០តាមខ្ញុំចាំហ្នឹងកាកបាទក្រហមគេម៉ោបើកអង្ករឲ្យផ្ទាល់ បើកឲ្យតែនារីៗទេ ទ័ពអត់ឲ្យទេឲ្យតែនារីៗហើយឲ្យតែកុមារ កុមារប្រុសក៏ដោយក៏ឲ្យដែរឲ្យតែកុមារតែទ័ពអត់ទេហើយអ្នកពិការអ្នកជំងឺអីឲ្យតែចំពោះទ័ពគេអត់ឲ្យទេ ចុះគេឲ្យទៅមានកំលាំងច្បាំងគ្នាហើយអត់ឲ្យទេ ។

ដានី ៖ ចុះនារីហ្នឹងអត់មានលួចឲ្យកងទ័ពទេ?

គុំ ៖ លួចដែរហ្នឹង ដូចថាគេដឹកឲ្យនារីហូបមួយអាទិត្យអញ្ចឹង យើងរំលែកទៅទុកហូបខ្វះទៅឲ្យគេខ្វះទៅ

ដានី ៖ កាលហ្នឹងគ្នាច្រើនទេ?

គុំ ៖ កាលហ្នឹងគ្នាច្រើនដែរ

ដានី ៖ ប្រហែលប៉ុន្មានមីងចាំទេនៅម៉ាឡៃមានតែភូមិដូងទេកាលជំនាន់ហ្នឹង?

គុំ ៖ ចា៎! នៅម៉ាជុំវិញមានតាំងពីខ្វាងរាប់តាំងអីម៉ោ

ដានី ៖ ប្រហែលប៉ុន្មានទៅមីងតាមការប៉ាន់ស្មានទៅ?

គុំ ៖ បើខ្ញុំប៉ាន់ស្មានទៅរាប់ពាន់ដែរទៅ ទាំងទ័ព ទាំងនារីដឹកជញ្ជូន តាំងពីពេទ្យសរុបទៅច្រើនដែរហ្នឹង

ដានី ៖ កាលហ្នឹងយ៉ាងម៉េចទៅទិដ្ឋភាពនៅម៉ាឡៃកាលឆ្នាំ៧៩?

គុំ ៖ ៧៩ដំបូងចាញ់ដែរ ដល់នៅយូរៗពេលកាកបាទក្រហមឲ្យម៉ោមានពេទ្យមានអីគេឲ្យថ្នាំបំបាត់គ្រុនចាញ់ក៏អន់ទៅអត់សូវគ្រុនចាញ់ប៉ុន្មានទេ ។

ដានី ៖ ចុះកាលពីមីងមកនៅដំបូងមកកន្លែងភូមិដូង កន្លែងនេះហ្នឹងមីងប្រៀបធៀបកាលឆ្នាំ៧៩ម៉ោកាលហ្នឹងយ៉ាងម៉េចដូចថាកន្លែងភូមិស្រុកយ៉ាងម៉េចដែរដូចឥឡូវប្ញក៏ខុស?

គុំ ៖ ខុសពីឥឡូវតែកាលពីមិនទាន់សម៉ានិរន្តកម្មនៅស្រួលម្យ៉ាងពិបាកម្យ៉ាង ស្រួលត្រង់ថាបើយើងចង់ទៅដេកថៃអីទៅបានតាមចិត្ត ហើយនៅៗមានផ្ទះអញ្ចឹងអ៊ីវ៉ាន់អីដាក់ចោលក្រោមផ្ទះអត់មានភ័យខ្លាចពីណាលួចទេទុកចោលកង់ម៉ូតូចង់ទៅថៃទៅបាត់ទៅ ទៅមើលស្អី ធ្វើការស៊ីឈ្នួលគេទៅហើយអីវ៉ាន់នៅពេញក្រោមផ្ទះអត់មានខ្លាចពីណាលួចទេហើយ ចេញចូលទៅថៃក៏ស្រួលថៃក៏អត់ថាអីដែរដល់ពេលក្រោយម៉ោអាសមារណោកម្ម ហើយហ្នឹងប្រចបូកប្រចបល់នៅពីក្នុងមានប្រចបូកប្រចបល់ទៅថៃអត់បានទេ ហើយរបស់របរទុកប្រហែសក៏អត់បានដែរបាត់ ។

ដានី ៖ ចុះមីងដឹងពីមូលហេតុអី កាលមិនទាន់ធ្វើសមារណោកម គេឲ្យទៅថៃស្រួលគេឲ្យចេញចូលងាយ

ស្រួលក្នុងការចេញចូលដល់ផ្លូវគេតឹងតែង?

គុំ : តាមខ្ញុំយល់ខ្ញុំថាវានិយាយមួយមាត់ឲ្យខ្ញីវាមានអ្នកអាក្រក់មានអ្នកល្អ កាលជំនាន់នោះមិនមានប្លន់មិនមានលួចដល់ពេលក្រោយម៉ោ វាប្រឫកប្របល់យើងរកស៊ីៗវាមានលួចវាមានប្លន់ដល់អញ្ចឹងវាតឹងតែងអាហ្នឹង ខ្ញុំយល់អញ្ចឹងតែរឿងអាអីផ្សេងៗខ្ញុំអត់ដឹង ។

ដានី : បាទ!មួយទៀតដែលខ្ញុំចង់ដឹងទាក់ទងពីភូមិវិញ កាលពីជំនាន់ឆ្នាំ៧៩កាលហ្នឹងមានផ្ទះ មានផ្លូវដូចផ្លូវដែរឬក៏ម៉េច?

គុំ : អត់គ្មានដូច គ្មានផ្លូវអីកាលហ្នឹងមានតែផ្លូវយើងដើរធម្មតាដើរនឹងជើងមិនមានថ្នល់អីដូចផ្លូវអត់មានទេ ។

ដានី : ចុះកាលមុនឆ្នាំ៧៩មានភូមិដែរឬអត់មីង?

គុំ : អត់មានទេព្រៃសុទ្ធបើអ្នកនេះចាញ់ ។

ដានី : ចុះកាលឆ្នាំ៧៩ហ្នឹងព្រៃសុទ្ធដែរ?

គុំ : សុទ្ធតែព្រៃ

ដានី : ព្រៃអីខ្លះទៅបើតាមមីងចាំ?

គុំ : ព្រៃដើមឈើធំៗដើមតូចៗមិនដឹងស្អីខ្លះទេខ្ញុំមិនដឹងទេ

ដានី : យើងធ្វើផ្ទះនៅក្នុងព្រៃនឹងទៅ?

គុំ : ចា៎ៗធ្វើនៅក្នុងព្រៃអាស្សីបើកន្ទែងដាំទឹកព្រៃអាស្សី បើថាតាមមាត់អូរសុទ្ធតែព្រៃដូចជាព្រៃមិនដឹងដើមអីៗខ្លះទេសុទ្ធតែព្រៃខ្ញុំមិនសូវចាំទេ ។

ដានី : កាលហ្នឹងរាប់ពាន់នាក់ដែរ?

គុំ : ចា៎!កាលដំបូងចាញ់ណាស់មកនៅម៉ាឡៃដំបូងចាញ់ណាស់ ហើយមកនៅយូរៗដូចថាសាំមហើយម្យ៉ាងទៀតកាលហ្នឹងពេទ្យ កាកបាទគេជួយនោះមានឲ្យលេបថ្នាំលេបអីការពារនោះលេបការពារកំណត់ដូចថា១០ថ្ងៃលេបម្តងឲ្យលេបអញ្ចឹង អ្នកដឹកជញ្ជូនចែកគ្នាដូចថាពេទ្យតាមកងឲ្យលេបហើយលែងចាញ់ហើយបើថាមានដើរទៅមុខទៅអញ្ចឹង គ្រុនចាញ់អីម៉ោវិញជួសឈាមដេកពេទ្យ

ដានី : ចុះកងទ័ពនៅម៉ាឡៃប៉ុន្មានកងពលដែរកាលហ្នឹង?

គុំ : ប៉ុន្មានទេខ្ញុំមិនសូវចាំដែរមួយកងពលទេដឹង ។

ដានី : ពីណាគេកាលហ្នឹងជាអ្នកមេបញ្ជាការ?

គុំ : កាលម៉ាហីកហ្នឹង តាភាព មេកងពលហើយក្រៅពីហ្នឹងសុទ្ធតែអ្នកដឹកនាំក្រោមៗដូចជាវាមានផ្នែកដូចថាខាងដឹកជញ្ជូន ខាងទ័ពហើយខាងក្រោយមានពូចៀមហ្នឹង ហើយពូហុង ពូចៀមគាត់អ្នកទាក់ទងខាងក្រោយរឿងស្បៀងហ្នឹង នឹងអ្នកលើៗទៀតខ្ញុំក៏មិនសូវស្គាល់ដែរស្គាល់តែអ្នក

ក្តាប់ផ្ទាល់ៗ ។

ដានី : ចុះពូហុងគាត់ក្តាប់ផ្ទាល់ដែរ?

គុំ : ពូហុងគាត់ក្តាប់ផ្ទាល់ដែរដូចថាគាត់ទៅខាងបរទេសផង គាត់មកក្តាប់យើងនៅខាងក្នុងនេះផង ហើយពូចៀមគាត់ក្តាប់ខាងស្បៀងហ្នឹងហើយពូសុភាពគាត់ខាងយោធា មានតែមួយកងពល ហ្នឹងឯងខាងយោធា ។

ដានី : បាទ!ចុះអ៊ីអៀងសារីគាត់ម៉ោ?

គុំ : ហ្នឹងគាត់ខាងបរទេសគាត់ម៉ោទាក់ទងមិនដឹងគាត់ទាក់ទង ស្អីខ្លះខ្ញុំមិនសូវដឹងដែរការងារគាត់ខ្ញុំមិន សូវដឹងដែរ ។

ដានី : ចុះអ្នកដឹកនាំផ្សេងទៀតអត់មានទេ?

គុំ : មានដែរតែខ្ញុំមិនសូវស្គាល់ទេ

ដានី : បាទ!ចុះកាលហ្នឹងដូចថាខាងកាកបាទក្រហមគេជំនួយម៉ោ កាលហ្នឹងការហូបចុកគ្រប់គ្រាន់ដែរឬ អត់កាលជំនាន់ហ្នឹង?

គុំ : ហូបគ្រប់ព្រោះកន្លះខែគេដឹកយកមកឲ្យម្តង

ដានី : គេដឹកយកមកឲ្យនៅកន្លែងណាទៅ?

គុំ : ដឹកមកឲ្យឥឡូវនេះហួសពីដាឡាត់ណាត់(ផ្សារណាត់) នេះទៅ បេះទៀតកន្លែងហ្នឹងមានព្រលានគេ ធ្វើព្រលានអំនៅហ្នឹង ។

ដានី : កាកបាទគេដឹកមកផ្ទាល់?

គុំ : ចា៎!គេដឹកមកផ្ទាល់ហើយគេចែកយើងទៅយកទៅសំរាប់នាក់កន្លះខែអាចមួយគោ

ដានី : ចុះម្ហូប?

គុំ : ម្ហូបមានត្រីកាម៉ុង មានត្រីខ ហើយកាលហ្នឹងត្រីខសុទ្ធតែកំប៉ុងវែងៗដែលគេហៅកំប៉ុងជប៉ុន នោះជំនួយពីជប៉ុនម៉ោនោះជំនួយមនុស្សធម៌នោះ ។

ដានី : ចុះក្រៅពីម្ហូបយើងអាចរកអីផ្សេងទៀតមក?

គុំ : អត់មានទេអត់រកអីបានទេវាមិនមានពេលរកផង

ដានី : យើងរវល់ធ្វើអីទៅ?

គុំ : រវល់ដឹកជញ្ជូន ទ័ពរវល់ការពារអញ្ចឹងទៅ

ដានី : កាលហ្នឹងយើងវៃគ្នាខ្លាំងទេកាលហ្នឹង?

គុំ : វៃខ្លាំងណាស់

ដានី : វៃនៅម្តុំណា?

គុំ ៖ វ៉ៃនៅខាងមុខៗខ្ញុំមិនដែលបានទៅដល់មុខដែរនៅម៉ាជយរម៉ក់ហឿនអីណាទុំះ

ដានី ៖ ម៉ក់ហឿនហ្នឹងស្អីគេ?

គុំ ៖ ម៉ក់ហឿនជាទីតាំងមួយទីតាំងទាហាន

ដានី ៖ ឈ្មោះភូមិ ស្រុកឬក៏ស្អីគេ?

គុំ ៖ ឈ្មោះភ្នំម៉ក់ហើនហ្នឹង ហើយគេហៅភ្នំម៉ាឡៃកាលហ្នឹងយួនវាមកនៅភ្នំម៉ាឡៃ

ដានី ៖ ភ្នំម៉ាឡៃកន្លែងណាទៅ?

គុំ ៖ ភ្នំម៉ាឡៃហ្នឹងឥឡូវហ្នឹងសុទ្ធតែចំការអស់ហើយ

ដានី ៖ ភ្នំហ្នឹងគេធ្វើចំការអស់ហើយ?

គុំ ៖ ភ្នំហ្នឹងគេមិនធ្វើទេតែនៅជុំវិញជើងភ្នំហ្នឹងគេធ្វើចំការអស់ហើយ

ដានី ៖ នៅណាភ្នំហ្នឹង?

គុំ ៖ នោះនៅឯមុខហ្នឹងនៅគេហៅភ្នំពិបាកថាណាស់ព្រោះមិនដែលទៅអញ្ចឹង

ដានី ៖ បាទ!ភ្នំហ្នឹងកន្លែងគេវ៉ៃច្បាំងដែរ?

គុំ ៖ ភ្នំម៉ាឡៃគេហៅជាភ្នំម៉ាឡៃតែមែនទែនគេហៅភ្នំទឹកចេញ គេហៅភ្នំវ៉ាងគេហៅភ្នំកន្លែងគេដាក់កាំភ្លើងធំគេហៅភ្នំកាំភ្លើងធំអញ្ចឹងទៅណា ។

ដានី ៖ អូ៎!ភ្នំទាំងអស់រួមទៅគេហៅភ្នំម៉ាឡៃប៉ុន្តែភ្នំតូចៗគេហៅភ្នំវ៉ាង ភ្នំទឹកចេញ ភ្នំក្បាលដំរី ភ្នំវែងភ្នំហើយជាទូទៅគេហៅភ្នំម៉ាឡៃ?

គុំ ៖ ចាំ!ជាទូទៅគេហៅភ្នំម៉ាឡៃ

ដានី ៖ ចុះភ្នំម៉ក់ហឿន?

គុំ ៖ ភ្នំម៉ក់ហឿននៅខាងឯម៉ក់ហឿនតែគេថាភ្នំក៏មិនធំប៉ុន្មានដែរតូចដែរ ។

ដានី ៖ អូ៎!អញ្ចឹងប៉ុន្តែសមរភូមិវ៉ៃខ្លាំងនៅម្តុំណា?

គុំ ៖ វ៉ៃខ្លាំងមិនដឹងនៅត្រង់ណាត្រង់ណីទេខ្ញុំភ្លេចអស់ហើយ

ដានី ៖ មីងអត់ដែរទៅវ៉ៃនឹងគេទេ?

គុំ ៖ ខ្ញុំមិនដែលទៅទេដែលតែដឹកជញ្ជូន ដឹកជញ្ជូនក៏ដឹកជញ្ជូននៅខាងក្រោយដែរ ដូចយកពីនេះទៅដាក់ទីនោះមួយទៅដាក់ខ្លាំងរាប់តាមព្រំដែនដែរអត់ដែលទៅដល់មុខទេ ។

ដានី ៖ ចុះកាលហ្នឹងមីងមានផ្ទះមានអីនៅឬអត់?

គុំ ៖ ផ្ទះតូចៗ

ដានី ៖ គេធ្វើឡ?

គុំ ៖ ធ្វើខ្ទមឯងនារីដឹកជញ្ជូនធ្វើខ្ទមឯងមួយក្រុមៗ

ដានី ៖ នៅម៉ាក្រុមៗ អញ្ចឹងទៅអត់នៅម្នាក់ៗឯងទេ?

គុំ ៖ អត់ទេអត់មាននៅម្នាក់ឯងទេនៅមួយក្រុមតែម្តង ម៉ាក្រុម១០នាក់ឬ១៣នាក់ម៉ាកងតូច ៣០នាក់ ។

ដានី ៖ ធ្វើផ្ទះម៉េចទៅ?

គុំ ៖ ផ្ទះប្រកស្បូវកាប់សសរប៉ុនៗ នេះនាំគ្នាធ្វើដូចខ្ទមស្រែអញ្ចឹង បិនដូចថាម៉ាកងនៅម៉ាកណ្តុំៗ ម៉ាក្រុមផ្ទះមួយៗ ។

ដានី ៖ នៅរហូតដល់ពេលណាទៅ?

គុំ ៖ នៅរហូតដល់ពេលបែក៨៥កាលហ្នឹងយួនបុកម៉ោវ៉ៃ ដាច់ម៉ាឡៃទៅនៅដីថៃចេញពីដីថៃមកនៅមកនៅកន្លែងហ្នឹងដដែលទៀត ។

ដានី ៖ ដីថៃនៅម៉ាម្តុំណា?

គុំ ៖ នៅ៨៥ នៅជួរហួសខ្លងហ៊ាតទៅបន្តិចនេះ

ដានី ៖ កាលហ្នឹងយួនវាមកវ៉ៃចូល?

គុំ ៖ វាមកនៅព្រំដែន វាវ៉ៃដាច់អស់ហើយយើងឈ្លបទៅវ៉ៃពីក្នុងមកវិញ

ដានី ៖ វ៉ៃពីដីថៃមកវិញ?

គុំ ៖ វ៉ៃពីក្នុងមកពីខាងអូពិល ខាងដុងហិរញ្ញនោះមកវិញ ទ័ពទៅខាងក្នុងមកវិញ ព្រំដែនមានតែយួនទេ

ដានី ៖ អញ្ចឹងបានន័យថាយើងទៅព័ទ្ធពីក្រោយយួនវិញ?

គុំ ៖ ចា៎!យួននៅព្រំដែនដែលទ័ពទៅវ៉ៃពីក្នុងមកវិញ

ដានី ៖ ចុះបើមីងៗ ទៅដល់ដីថៃហើយ?

គុំ៖ ខ្ញុំគ្រួសារទ័ពទៅនៅដីថៃមានដឹកជញ្ជូនទៅជាមួយទ័ពទៅក្នុងដែរទៅណាទេខ្ញុំមិនសូវស្គាល់ដែរ

ដានី ៖ ចុះមីងនៅដីថៃអស់រយៈពេលប៉ុន្មានដែរ?

គុំ ៖ នៅពី៨៥មកដល់៩០

ដានី ៖ កាលហ្នឹងមីងមានគ្រួសារឬនៅ?

គុំ ៖ មានហើយ

ដានី ៖ មីងការនៅឆ្នាំណា?

គុំ ៖ ការឆ្នាំ៨៥ហ្នឹង

ដានី ៖ កាលមីងរៀបការនៅឯណា?

គុំ៖ រៀបការទៅប៉ៃលិនហ្នឹងទៅដល់ដីថៃគេមានអ្នកទៅជុំរុំ ហើយអ្នកភៀសខ្លួនទៅប៉ៃលិនដល់ទៅៗ

ដល់ទៅរៀបការនៅប៉ៃលិនហ្នឹង ។

ដានី ៖ កាលឆ្នាំ៨៥យួនវ៉ៃបែកម៉ាឡៃទៅមីងរត់ទៅប៉ៃលិន?

គុំ ៖ ចាំ!

ដានី ៖ ដល់ទៅប៉ៃលិនទៅរៀបការនៅប៉ៃលិន?

គុំ ៖ ចាំ!ហើយបានត្រលប់មកវិញនៅ៨៥ ។

ដានី ៖ ចុះកាលហ្នឹងម៉េចបានមីងទៅដល់ដីថៃមីងរៀបកា មីងអាចរៀបរាប់ប្រាប់ខ្ញុំបានទេប្រាប់ពីប្រវត្តិមីង?

គុំ ៖ ព្រោះនឹងទៅនៅនោះខ្ញុំមានគូរដណ្ដឹងពីនេះរួចហើយ ដល់រត់ទៅអ្នកដឹកនាំគេឲ្យរៀបការនៅហ្នឹង

ដានី ៖ កាលហ្នឹងប្ដីមីងគេធ្វើអី?

គុំ ៖ ទ័ព កាលហ្នឹងមុនទៅនឹងគាត់នៅខាងទូរលេខ

ដានី ៖ ខាងកងពលរបស់អើ?

គុំ ៖ នៅជាមួយពួហុងហ្នឹង

ដានី ៖ នៅជាមួយពួហុងទេ?

គុំ ៖ ចាំ!

ដានី ៖ មិននៅជាមួយសុភាពទេ?

គុំ ៖ អត់ទេ!

ដានី ៖ គាត់កាន់ខាងទូរលេខ អញ្ចឹងពួហុងគាត់មានទ័ពទេ?

គុំ ៖ គាត់អត់មានទ័ពទេគាត់ខាងទាក់ទងខាងក្រៅប្រទេស

ដានី ៖ ប៉ុន្តែគ្រួសារមីងគាត់ធ្វើទ័ព?

គុំ ៖ ធ្វើ ដល់ក្រោយមកទើបគាត់ទៅប្រចាំការជាមួយទ័ពមុខយកទូរលេខនឹងទៅប្រចាំការនៅនោះដែរ

ដានី ៖ ឆ្នាំណាមីង?

គុំ ៖ ឆ្នាំ៨១-៨២ ៨២ហ្នឹងគាត់ទៅនៅមុខធ្វើជាមួយតាមកងពលដូចជាកងធំតាមផ្នែកៗហ្នឹង

ដានី ៖ តាមផ្នែកៗហ្នឹងកងពលរបស់អើ?

គុំ ៖ របស់ពួភាពដែលហ្នឹង

ដានី ៖ អញ្ចឹងគាត់បែកពីពួហុង?

គុំ ៖ អត់បែកទេសហការណ៍ជាមួយគ្នាទាំងអស់ហ្នឹង

ដានី ៖ ប៉ុន្តែគាត់នៅក្រោមការគ្រប់គ្រងរបស់ពួហុងដដែល?

គុំ ៖ ចា៎!ដូចថាគេហៅថាជំនួយការណ៍អញ្ចឹងដូចពេលមុខខ្លះយកពីហ្នឹងទៅ ។

ដានី ៖ បាទ!ចុះមីងជួបគាត់យ៉ាងម៉េចខ្ញុំដឹងថា មីងជួបគាត់នៅពេលណាហើយយើងចាប់ផ្ដើមស្រលាញ់គ្នា?

គុំ ៖ មែនទែនគាត់ស្គាល់គ្នាតាំងពីតូចៗតាំងពីស្រុកម៉ោ ។

ដានី ៖ ពីស្រុកណា?

គុំ ៖ នៅហ្នឹងដូចគ្នានៅខាងកំពង់ធំដូចគ្នា

ដានី ៖ គាត់នៅខាងកំពង់ធំ អញ្ចឹងគាត់ស្គាល់មីងតាំងពីមីងមិនទាន់ចេញពីផ្ទះ?

គុំ ៖ ស្គាល់តាំងពីហ្នឹងហើយ

ដានី ៖ ស្រុក ភូមិ ឃុំនៅជាមួយគ្នា?

គុំ ៖ ភូមិអត់ជាមួយទេ ឃុំជាមួយគ្នាតែដល់ចូលជួរម៉ោនៅកន្លែងជិតគ្នា ដល់ពេលគាត់កាលហ្នឹងគាត់មុនអាកាល៧៩គាត់អត់មាននៅទីនេះទេគាត់អត់បានរត់ទេគាត់ទៅចិន ។

ដានី ៖ គាត់ទៅចិន?

គុំ ៖ ចា៎!គាត់ទៅខាងទូរលេខហ្នឹង

ដានី ៖ គាត់ទៅចិននៅឆ្នាំណា?

គុំ ៖ ទៅមុនឆ្នាំ៧៩មុនប្រហែលចុង៧៨ហ្នឹងដឹង

ដានី ៖ បាទ!ហើយឆ្នាំណាគាត់មកវិញ?

គុំ ៖ ឆ្នាំ៨២គាត់មកវិញ

ដានី ៖ គាត់មកវិញគាត់នៅណា?

គុំ ៖ មកនៅហ្នឹងដដែល

ដានី ៖ ហើយយ៉ាងម៉េចទៅពេលហ្នឹង? មិញថាឆ្នាំ៨២គាត់ម៉ោហើយម៉េចបានគាត់ស្គាល់មីង យ៉ាងម៉េចទាក់ទងគ្នាម៉េច?

គុំ ៖ ស្គាល់តាមបងប្អូន សាច់ញាតិខ្ញុំដែលស្គាល់គ្នាមកតាមគ្នាតាំងពីហ្នឹងម៉ោទុកចិត្តទុកច្បើមគ្នាទៅ

ដានី ៖ ចុះមីងអុីមីងបានស្រឡាញ់ជាមួយគាត់បានប៉ុន្មានឆ្នាំទើបរៀបការ?

គុំ ៖ តាំងពី៨២មក ការ៨៥

ដានី ៖ អញ្ចឹងមីងមានចិត្តមានផ្ទើមជាមួយគ្នាតាំងពីឆ្នាំ៨២ដល់ពេលរៀបការឆ្នាំ៨៥?

គុំ ៖ ចា៎!

ដានី ៖ ម៉េចបានគាត់ទៅប៉ៃលិនដែរ?

គុំ ៖ រត់ជាមួយគ្នាហ្នឹង

ដានី ៖ គាត់អាយុច្រើនជាងមីងប៉ុន្មានឆ្នាំ?

គុំ ៖ អយុច្រើនជាងខ្ញុំ៣-៤ឆ្នាំទេខ្ញុំមិនសូវចាំដែរ

ដានី ៖ បាទ!ទៅដល់ប៉ៃលិនពីណាគេជាអ្នកផ្សំផ្គុំឲ្យ?

គុំ ៖ អ្នកនៅហ្នឹងពូ ចៀមហ្នឹង

ដានី ៖ កាលហ្នឹងផ្សំផ្គុំតែមីងមួយគូរឬមានគ្នាច្រើន?

គុំ ៖ អត់ទេគ្នាច្រើន

ដានី ៖ គ្នាច្រើនប៉ុន្មានគូរដែរកាលហ្នឹងមីងចាំទេ?

គុំ ៖ កាលជំនាន់ខ្ញុំហ្នឹង៨គូរ

ដានី ៖ គូរណាខ្លះ?

គុំ ៖ អ៊ូបែកអស់ហើយឥឡូវស្លាប់ខ្លះ

ដានី ៖ អ្នកណាខ្លះនៅកន្លែងមីង?

គុំ ៖ ឥឡូវខ្ញុំចាំតែ២-៣នាក់ទេ

ដានី ៖ អ្នកណាខ្លះ?

គុំ ៖ ពូ វ៉ន

ដានី ៖ គាត់នៅឯណាពូវ៉ន?

គុំ ៖ គាត់ធ្វើការទៅមកទៅមកទៅនៅអើនេះ!

ដានី ៖ ទៅនៅណា?

គុំ ៖ មិនដឹងគាត់ទៅនៅណាទេទៅនៅភ្នំពេញដឹង

ដានី ៖ អញ្ចឹងផ្ទះគាត់នៅម៉ាឡៃហ្នឹងដែរ?

គុំ ៖ ចា៎!ផ្ទះគាត់នៅនេះ

ដានី ៖ ចុះប្រពន្ធគាត់

គុំ ៖ ប្រពន្ធគាត់ទៅមកៗភ្នំពេញកូនរៀននៅភ្នំពេញគាត់ទៅភ្នំពេញដែរ

ដានី ៖ គាត់ធ្វើអីគេ?

គុំ ៖ គាត់មិនដឹងធ្វើអីទេការងារគាត់ខ្ញុំមិនសូវដឹងដែរ

ដានី ៖ មួយទៀតនៅ៩៣?

គុំ ៖ ចា៎!

ដានី ៖ ឈ្មោះអីទៅ?

គុំ ៖ ឈ្មោះពូ វ៉ាត

ដានី ៖ ៩៣កន្លែងវត្ត៩៣ហ្នឹង?

គុំ ៖ ចា៎!

ដានី ៖ ហើអ្នកណាទៀត?

គុំ ៖ អូខ្ញុំក្មេចអស់ បើម៉ាគ្រួសារទៀតនៅជិតនេះឥឡូវស្លាប់អស់ទាំងប្ដីទាំងប្រពន្ធ ។

ដានី ៖ ប្ដីបានស្លាប់អស់?

គុំ ៖ គាត់ឈឺ ប្រពន្ធគាត់ទឹកនោមផ្អែម ប្ដីគាត់គេថារបេងឆ្អឹង ហើយខ្ញុំមិនដឹងទៅណាទៀតទេបែកគ្នាអស់ហើយ ។

ដានី ៖ បាទ!ចុះពេលមីងរៀបការនៅប៉ៃលិនហ្នឹង មីងការបានរយៈពេលប៉ុន្មានទើបបានទៅនៅ៨៥ដីថៃ?

គុំ ៖ ការបាន២-៣ខែទៅនៅ៨៥

ដានី ៖ នៅជាមួយគ្នាបាន២-៣ខែហើយមីងទៅនៅ៨៥ទាំងអស់គ្នាឬយ៉ាងម៉េច?

គុំ ៖ ចា៎!ទៅនៅទាំងអស់គ្នាៗហើយបានគាត់ទៅតាមទ័ពទៅ ខាងមុខគាត់កាន់ទូរលេខហ្នឹងទៅតាមទ័ពទៅមុខ ។

ដានី ៖ ទៅទាំងអស់គ្នាឬទៅតែគាត់?

គុំ ៖ ទៅតែគាត់

ដានី ៖ ឆ្នាំណាបានគាត់ត្រឡប់មកនៅនេះវិញ?

គុំ ៖ គាត់ទៅម៉ោៗដូចថាទៅកន្លះឆ្នាំឬមួយឆ្នាំអីម៉ោក្រោលមួយដងអញ្ចឹងទៅ

ដានី ៖ អញ្ចឹងពេលដែលការហើយឆ្នាំ៨៥ហ្នឹងមីងទៅនៅដីថៃ នៅកន្លែង៨៥ហ្នឹងហើយគាត់ក៏ចេញម៉ោ

គុំ ៖ គាត់ចេញទៅតាមទ័ពអញ្ចឹងទៅ ។

ដានី ៖ គាត់ទៅនៅដីថៃបានយូរដែរឬអត់បានចេញ?

គុំ ៖ ទៅជាមួយគ្នាហ្នឹង បើចេញម៉ោនេះមកជាមួយគ្នាដែរ

ដានី ៖ ប៉ុន្តែគាត់ចេញមកតាមកងទ័ពដូចថាគាត់ទៅនៅដីថៃបានរយៈពេលប៉ុន្មាន?

គុំ ៖ គាត់ទៅបានរយៈពេលមួយខែឬពីរខែមកមុខ មកបានរយៈ៦ខែបានទៅត្រឡប់ទៅវិញ១-២ខែបានទៅទៀតទៅ

ដានី ៖ អ៊ូ!ចុះមីងកូនមីងកូនទី១ឆ្នាំ៨៥ហ្នឹង?

គុំ ៖ ចុង៨៥ហ្នឹងជិតដាច់ដែរហើយ

ដានី ៖ កាលហ្នឹងមីងឆ្លងទន្លេនៅដីថៃ

គុំ ៖ ចា៎!

ដានី ៖ យ៉ាងម៉េចដែលកាលហ្នឹងមានការពិបាក?

គុំ ៖ អត់អីទេមានពេទ្យ មានពេទ្យបន្ថែករឹងមាំដែរនៅហ្នឹង

ដានី ៖ នៅដីថៃបានប៉ុន្មានឆ្នាំ?

គុំ ៖ នៅបាន៩ឆ្នាំ

ដានី ៖ ចុះមីងចេះនិយាយភាសាថៃឬអត់?

គុំ ៖ ចេះតិចតួច អត់ចេះទៅនៅដីថៃ៩ឆ្នាំមកវិញខ្មែររូ

ដានី ៖ ម៉េចអញ្ជឹង? ដោយសារយើងនៅក្នុងហ្នឹងអត់បានចេញទៅ?

គុំ ៖ អត់បានចេញទៅនិយាយចេញទៅ

ដានី ៖ ហើអើឆ្នាំ៩០ បានយើងមកដីខ្មែរមក

គុំ ៖ ចា៎!ឆ្នាំ៩០ បានមកដីខ្មែរវិញ

ដានី ៖ ម៉េចបានមកដីខ្មែរវិញ?

គុំ ៖ ព្រោះកាលហ្នឹងរំដោះរួចអស់ហើយទាហានខ្មែររត់អស់ហើយ នៅអត់បាន

ដានី ៖ ទាហានខ្មែរណា?

គុំ ៖ ទាហានពីខ្មែរយើងរបស់រាជរដ្ឋាភិបាលហ្នឹង

ដានី ៖ ទាហានខាងក្នុង ខាងរដ្ឋកម្ពុជា?

គុំ ៖ ចា៎!

ដានី ៖ ចុះខាងយួន?

គុំ ៖ ខាងយួនដកចេញអស់ហើយ

ដានី ៖ ដកចេញអស់ហើយយើងម៉ោវិញ?

គុំ ៖ ចា៎ម៉ោវិញមកដល់ដំបូង តាមនេះអីសុទ្ធតែមីនតាមមាត់អូរ

ដានី ៖ មីនខាងណាអ្នកដាក់?

គុំ ៖ ខាងរដ្ឋកម្ពុជាហ្នឹងអ្នកដាក់

ដានី ៖ ចុះម៉េចទៅសុទ្ធតែមីនអញ្ជឹង?

គុំ ៖ ម៉ោឈូសៗធ្វើកន្លែងបន្តិចៗនៅ ហើយប្អូនខ្ញុំស្លាប់មិនមែនប្អូនបង្កើតទេរាប់អានគ្នាដូចបងប្អូន បង្កើតអញ្ជឹងឈូសដីស្លាប់ម្នាក់នៅក្រោយ ។

ដានី ៖ ស្លាប់ដោយសារ?

គុំ ៖ ស្លាប់ដោយសារឈូសដីផ្ទុះមីនឈូសមីនយកដីដាំដំនាំផ្ទុះមីនស្លាប់ទៅ ឥឡូវប្រពន្ធក៏ស្លាប់ទៀត ឈឺ ។

ដានី ៖ ចុះអើកាលហ្នឹងម៉េចបានកាលហ្នឹងឆ្នាំ៩០ម៉ោពីដីថៃវិញ គេបញ្ជូនមកវិញយើងស្ម័គ្រចិត្តម៉ោវិញ?

គុំ ៖ យើងអ្នកដឹកនាំយើង ចុះរំដោះបានហើយម៉ោវិញ

ដានី ៖ បាទ!កាលហ្នឹងម៉ោប៉ុន្មានទៅកាលឆ្នាំ៩០ម៉ោគ្នាច្រើនទេ?

គុំ ៖ ម៉ោគ្នាច្រើនរាប់ពាន់គ្រួសារ

ដានី ៖ អ្នកដែលទៅប៉ុន្មានមកវិញទាំងអស់?

គុំ ៖ ចាំ!មកវិញទាំងអស់

ដានី ៖ កាលហ្នឹងអ្នកដែលនៅម៉ាឡៃទាំងអស់ទៅ៨៥ទៅនៅដីថៃទាំងអស់ហើយដល់ពេលឆ្នាំ៩០គាត់មកវិញទាំងអស់?

គុំ ៖ ចាំ!មានខ្លះហួសទៅនៅជំរុំតាង៉ុកទៅអភិវឌ្ឍន៍ទៅស្រុកខ្មែរ ដែរកាល៩៣ហ្នឹងអភិវឌ្ឍន៍ដូចស្រុកខ្មែរដែរ ។

ដានី ៖ ចុះមីងដល់ពេលម៉ោនៅហ្នឹងវិញឆ្នាំ៩០ពិបាកឬក៏ស្រួល?

គុំ ៖ ពិបាកត្រង់មីនហ្នឹង

ដានី ៖ បាទ!ហើយកាលហ្នឹងយើងនៅទទួលបានរបបដដែលឬអត់?

គុំ ៖ របបហូបចុកពីផ្ទះ ពីអ្នកដឹកនាំដដែល

ដានី ៖ ពីអ្នកដឹកនាំដដែលពីកាកបាទក្រហមដដែល?

គុំ ៖ ពីមិនមែនកាកបាទក្រហមទេអ្នកដូចថាមិនដឹងដែរគេដឹកម៉ោ ឲ្យខាងថ្នាក់ដឹកនាំយើងទាក់ទងមិនដឹងទិញអង្ករថៃម៉ោចែកឲ្យ ។

ដានី ៖ ទិញអង្ករថៃមកចែកឲ្យ?

គុំ ៖ ចាំ!

ដានី ៖ អញ្ចឹងកាលហ្នឹងយើងអត់ទាន់ធ្វើចំការទេ?

គុំ ៖ អត់ទាន់ធ្វើទេ មកដល់ដំបូងមិនទាន់ធ្វើស្រែធ្វើចំការទេទើបនឹងឆ្នាំប៉ុន្មានទេខ្ញុំឆ្នាំ៩០ជាងធ្វើស្រែធ្វើចំការខ្លួនឯង ក៏មិនទាន់ធ្វើខ្លួនឯងបានហូបគ្រប់ដែរនៅដូចថាមានរបបហូបបន្ថែមផងធ្វើស្រែធ្វើចំការខ្លួនឯងផង ។

ដានី ៖ អឺទៅណា?

គុំ ៖ ទៅស្រែបាត់ហើយ

ដានី ៖ កាលហ្នឹងយើងធ្វើស្រែមុនពេលសមារណកម្មឬក៏ធ្វើមុនពេលហ្នឹង?

គុំ ៖ ធ្វើមុនសមារន្តណកម្មយូរដែរ

ដានី ៖ ចុះកាលហ្នឹងមានមីនច្រើនកាលមុនឆ្នាំ៩០ យើងចូលម៉ោ?

គុំ ៖ មីនច្រើនមីននៅតាមមាត់អូរ ហើយតាមរបងលួសដួរនេះសុទ្ធតែមីនដឹក្រោយម៉ោបានស៊ីម៉ាក់ដោះ ។

ដានី ៖ ចុះកាលមីនច្រើនអញ្ចឹងយើងអត់សូវហ៊ានដើរ?

គុំ ៖ អត់សូវហ៊ានដើរ ដើរទាំងថុយទាំងប្រថាន

ដានី ៖ មានផ្ទុះច្រើនដែរ?

គុំ ៖ ផ្ទុះដើរទៅជួនកាលដើរផ្លូវហ្នឹងគេទៅមិនអីយើងទៅក្រោយខុសតែគេបន្តិចត្រូវដាច់ជើងទៅ

ដានី ៖ គេត្រូវអ្នកដែលត្រូវរបួសដោយសារមីនទៅព្យាបាលនៅណាទៅ?

គុំ ៖ ពេទ្យយើងហ្នឹងពេទ្យបង្អែកនៅភូមិដូងហ្នឹង

ដានី ៖ កាលហ្នឹងយ៉ាងម៉េចដែរមីងនៅចំាជីវិតពីឆ្នាំ៩០ មកដល់សមាហរណកម្មហ្នឹងយ៉ាងម៉េចដែរ? ស្រួលឬក៏ពិបាក?

គុំ ៖ ខ្ញុំថាម្យ៉ាងម្នាក់

ដានី ៖ ម្យ៉ាងយ៉ាងម៉េចទៅ?

គុំ ៖ សម័យនោះយើងធ្វើស្រែបានបន្តិចបន្តួចតែមានដូចថាខបត្តមអង្ករអីទៅហូបគ្រប់គ្រាន់ មិនមានទេតែក៏មិនអត់ដែរម៉ោឥឡូវនេះរកបានឃើញមានផ្ទះធំ ផ្ទះអីជួនកាលអត់ដែរវាម្យ៉ាងម្នាក់កាលនោះគ្មានផ្លូវដើរគ្មានអីឥឡូវយើងមានផ្លូវអញ្ចឹងទៅ បានទៅស្គាល់ផ្លូវទៅស្វាយ ទៅកាលមុនគ្មានទៅណារួចទេនៅតែជុំវិញហ្នឹង ។

ដានី ៖ ប៉ុន្តែយើងទៅណាអត់រួចយើងមានហូបចុកគ្រប់គ្រាន់?

គុំ ៖ ចា៎! ហូបចុកវាមិនសំបូរពេកហើយក៏មិនអត់ពេកដែរ ។

ដានី ៖ ឥឡូវដូចមីងថាមានផ្ទះធំប៉ុន្តែជួនកាលអត់ដែរ អត់យ៉ាងម៉េច?

គុំ ៖ ដូចថារកលុយអត់បានអញ្ចឹងដូចជាឥឡូវរបស់ក៏ថ្លៃរកលុយក៏មិនសូវបាន

ដានី ៖ អញ្ចឹងតាំងពីសមាហរណកម្មម៉ោយើងដូចដីធ្លីផ្ទះសម្បែងអីគេចែកឲ្យយើងឬក៏យ៉ាងម៉េច?

គុំ ៖ កាប់ខ្លួនឯង ដីចំការដូចថានាំគ្នាទៅកាប់ទៅបានដីហ្នឹងកាលហ្នឹងខ្ញុំបានដីតិចជាងគេព្រោះប្តីខ្ញុំទៅមុខទៅមុខទៅកាប់ព្រំកាប់អីហើយអញ្ចឹងគាត់ទៅមុខឆ្ងៀតមក ពីមុខហ្នឹងអារឈើជំនួយថែមបានលុយខ្លះហ្នឹងយកម៉ោកាប់ចំការហ្នឹងបានប៉ុណ្ណឹងគេបានរាប់រយ គេបានរាប់រយរ៉ៃគេមានលុយគេ ចេះតែទិញថែមទៅ ។

ដានី ៖ គេមានអ្នកផ្សេងគេបានរាប់រយរ៉ៃដែរ?

គុំ ៖ ចា៎!

ដានី ៖ សុទ្ធតែកាប់ខ្លួនឯងយើងរៀនកាប់ខ្លួនឯង?

គុំ ៖ កាប់ខ្លួនឯងដូចថាជួលគេកាប់ទៅ

ដានី ៖ ចុះមីងដូចថាមុនធ្វើសមារណកម្មម៉ោមីងធ្វើចំការ?

គុំ ៖ ធ្វើចំការ

ដានី ៖ ចុះប្តីមីង?

គុំ ៖ កាលពីមុនគាត់ធ្វើទាហ៊ានដល់ពេលសមារណកម្មឈប់ឲ្យបាញ់គ្នាហ្នឹងគាត់ឈប់ធ្វើទាហ៊ានតាំងពីហ្នឹងមករហូត ។

ដានី ៖ ឈប់ធ្វើទាហ៊ានគាត់ធ្វើអីទៅ?

គុំ ៖ ធ្វើតែស្រែចំការហ្នឹង ឥឡូវចំការជួលឲ្យគេគាត់នៅតែផ្ទះចិញ្ចឹមមាន់តិចតួចហ្នឹង

ដានី ៖ ចំការម៉េចអាចរៀបរាប់ប្រាប់ខ្ញុំបន្តិចទៀតដូចថាយើងធ្វើទៅបានផលយ៉ាងម៉េចៗដែរ?

គុំ ៖ កាលពីមុនដាំពោតតែមួយឆ្នាំដាំពោតមួយដងហើយចុងឆ្នាំដាំសណ្តែងហើយអត់អីប៉ុន្មានទេ បានហូបគ្រប់គ្រាន់វាមិនមានទេតែយើងបានហូបគ្រប់គ្រាន់ ដល់ពេលក្រោយម៉ោគេមិនសូវមានដាំដាំពោតទេសណ្តែក ដាំល្ងរ ឆ្នាំមុនដំបូងធ្វើសណ្តែកធ្វើល្ងរហ្នឹង ធ្វើពីដើមដៃ ចុះខ្ទីគេខ្ទីអង្គការ

ដានី ៖ ខ្ទីធាគារខាងណា?

គុំ ៖ ខាងសិលានិធិកាលហ្នឹងការ៣បាតយកទៅធ្វើល្ងរហ្នឹង ដល់ពេលខ្ទីការអត់គ្រប់យើងទៅខ្ទីឯកជនទៀត ខ្ទីឯកជនការហាសិបភាគរយដល់បានអាល្ងរហ្នឹងសងគេបានដើមធ្វើសណ្តែងៗបានទន់ខ្លះឆ្នាំក្រោយធ្វើល្ងរទៀតខូចដល់ចុងឆ្នាំដាក់សណ្តែកទៀត ខូចសណ្តែកទៀតឆ្នាំក្រោយធ្វើសណ្តែកទៀតខូចទៀតខូចពីរឆ្នាំខ្ញុំជំពាក់គេប្រាំម៉ឺន ។

ដានី ៖ ប្រាំម៉ឺនបាត?

គុំ ៖ ចា៎!

ដានី ៖ ហើយម៉េចបានសងគេ

គុំ ៖ កូនទៅថៃខ្លះ ចិញ្ចឹមជ្រូកខ្លះទៅយកអាលុយជួលចំការខ្លះម៉ោផ្សំគ្នាបានសងគេរួច

ដានី ៖ សងគេដោយសារកូនមីងទៅថៃរកលុយម៉ោហើយមីងចិញ្ចឹមជ្រូកមីងចិញ្ចឹមជ្រូកច្រើនទេ?

គុំ ៖ អត់ច្រើនប៉ុន្មានទេប្រាំក្បាលប្រាំមួយក្បាលអញ្ចឹងទៅ

ដានី ៖ ឥឡូវសងគេអស់ហើយ?

គុំ ៖ ឥឡូវសងគេរួចអស់ហើយ តែខ្ញុំអត់ហានខ្ចីគេធ្វើទៀតព្រោះខ្លាចលខូចទៀត

ដានី ៖ អញ្ចឹងចំការជួលឲ្យគេទាំងអស់?

គុំ ៖ ចា៎!ជួលឲ្យគេទាំងអស់

ដានី ៖ ជួលរយៈពេលប៉ុន្មានឆ្នាំហើយ?

គុំ ៖ រយៈជួលបីឆ្នាំហើយពាបុ៤ទេមើលខ្ញុំជួលឲ្យគេ៤ឆ្នាំហើយ ដែលខ្ញុំថាលក់ដីហ្នឹងប្រមូលផល ហើយ សងគេអត់គ្រប់រកលក់ដីៗគេអត់ត្រូវការតែ៥ពាន់ គេអត់ត្រូវការបើលក់ទាបជាងហ្នឹងសងគេ មិនរួចដល់នេះចេះតែទុកៗទៅដល់នេះកូនគេថាមិនបាច់លក់ទេ ម៉ែខ្ញុំទៅថៃដល់កូនទៅថៃ បានម៉ោ ហើយខ្ញុំចិញ្ចឹមជ្រូកទៅបានលក់បណ្តោះការ គេកូនបានម៉ោសងគេ ហើយលុយជួលចំការបានម៉ោ ជុំគ្នាសងៗដោះៗរួចទៅ ។

ដានី ៖ ឥឡូវរួចប៉ុន្មានឆ្នាំហើយ?

គុំ ៖ រួចពីរឆ្នាំហើយ

ដានី ៖ ចុះមីងតាំងពី៧៩មកដល់ឥឡូវនេះមីងធ្លាប់ទៅលេងផ្ទះប៉ុន្មានដងហើយ?

គុំ ៖ អត់ដែលសោះ

ដានី ៖ អត់ដែលទៅលេងផ្ទះ?

គុំ ៖ ចាំ!អត់ដែលទេ ចង់ទៅដែរតែដូចថារកលុយមិនបានទៅ

ដានី ៖ ចុះមីងអត់នឹកអ៊ី?

គុំ ៖ នឹកចេះតែនឹកហើយស្រុកកំណើតតែមិនដឹងធ្វើម៉េចបើអត់លុយ ទ័លត្រឹមអត់លុយ

ដានី ៖ ចុះមីងមានដែលជួបបងប្អូនជួបឪពុកម្តាយ?

គុំ ៖ ជួបបងប្អូនមកលេង

ដានី ៖ គាត់មកលេងហ្នឹងដែរ?

គុំ ៖ ចាំ!ដូចថាគាត់មកលេង អញ្ចឹងយើងអាចរកឲ្យគាត់ធ្វើស៊ីហុយទៅវិញបានមួយពាន់ពីរពាន់អញ្ចឹង ទៅបើយើងអត់យើងអាចខ្ចីគេបាន ។

ដានី ៖ ចុះឪពុកម្តាយមីងគាត់ធ្លាប់មកលេងប៉ុន្មានដង?

គុំ ៖ ឪពុកខ្ញុំគាត់មកច្រើនដងហើយ៣-៤-៥ដងហើយ

ដានី ៖ ម៉ោតែឪពុក ម្តាយមីងគាត់ស្លាប់តាំងពីឆ្នាំ៧៩

គុំ ៖ ចាំ!ម្តាយចុងក៏អត់ម៉ោដែរម៉ោតែឪពុកហើយនឹងប្អូនៗ

ដានី ៖ ប្អូនពីរនាក់ក៏ធ្លាប់មកលេងនេះដែរ?

គុំ ៖ ចាំ!មួយទៀតធ្លាប់មកនៅបានជិតមួយឆ្នាំដែរប្អូនពៅគេ

ដានី ៖ គាត់ឈ្មោះអី?

គុំ ៖ ឈ្មោះ ផា គាត់មកនៅជិតបានមួយឆ្នាំដែរដល់ប្អូនមួយទៀតមកលេងយកទៅវិញ យកទៅហ្នឹងក្រោយមកវាមកលេងជាមួយឪពុកខ្ញុំមួយសារទៀត ។

ដានី ៖ ពុករបស់មីងគាត់មកច្រើនដងហើយ  មីងបែករយៈពេលប៉ុន្មានទៅបានជួបគាត់វិញ?

គុំ ៖ មើលបែកតាំងពីឆ្នាំ៧៣រហូតម៉ោឆ្នាំ៩៤-៩៥ បានគាត់មកលេង

ដានី ៖ គាត់មកលេងពេលសមារ៉ន្តូណកម្មហើយឬក៏មិនទាន់?

គុំ ៖ ចា៎!សមារណកម្មហើយ បានម៉ោលេង    នៅឆ្នាំ៩៦ប៉ុនដូចគាត់មៅ៉មុនម៉េចទេខ្ញុំភ្លេចដែរហើយ កាលហ្នឹងយូរហើយ ។

ដានី ៖ ចុះអើសាច់ញាតិមីងដូចថាមានញាតិមិត្តអ្នកស្រុកអ្នកភូមិអីមានដែរជួបគេដែរ?

គុំ ៖ ម៉ោជួបអ្នកស្រុកអ្នកភូមិគេម៉ោលេងអញ្ចឹងជួប  ប៉ុនបើខ្ញុំវិញអត់ដែលទៅសោះ

ដានី ៖ មីងអត់ដែលទៅអញ្ចឹងមីងមានដែរប៉ងទៅលេងស្រុកដែរឬអត់?

គុំ ៖ ប៉ងដែរហ្នឹងប៉ុនធ្វើម៉េចទេបើអត់លុយបងប្អូនចេះតែស្រែកថាចុះអត់មកលេងផ្ទះមកលេងស្រុក អីចង់ទៅដែរតែមិនដឹងធ្វើម៉េចមនុស្សយើងទ័លត្រឹមអត់ហើយចង់ហើយតែអត់ខ្ចីគេទៅក៏ពិបាក ម៉ោវិញមិនសងគេដដែលកាន់តែខ្លាំងទៀត

ដានី ៖ ចុះមីងដូចថាទាក់ទងនឹងមនោសញ្ចេតនាផ្ទាល់ខ្លួនរបស់មីងដូចថាកាលពីក្មេងមីងធ្លាប់រស់នៅជា មួយឪពុកម្តាយតាមស្រុកភូមិដល់ពេលបែកមកឥឡូវមីងមានគ្រួសារ    កូនចៅនៅហ្នឹងហើយក៏ មានញាតិមិត្តជិតខាងស្គាល់គ្នាជិតស្និតដូចថាមនោសញ្ចេតនាធ្លាប់រស់នៅហ្នឹងកាលពីតូចមីងរស់ នៅស្រុកកំណើតមីងមាននឹកស្រុក?

គុំ ៖ ដូចនឹកដែរតែដូចជាធម្មតាព្រោះនឹកឪពុកម៉ោធ្លាប់ឃើញគាត់មកលេង    គាត់នឹកគាត់មកលេង ដល់ពេលអ្នកស្រុកអ្នកភូមិនឹកគាត់ដែរតែមិនដឹងធ្វើម៉េចវាមិនាសញ្ចេនាចេះតែមានហើយ

ដានី ៖ មីងដូចថាយើងធ្លាប់រស់នៅនេះហើយរស់នៅនេះតើមួយណាមីងស្និតស្នាលជាង    នៅស្រុកភូមិ ឬយ៉ាងម៉េច?

គុំ ៖ និយាយទៅនៅនេះស្និតស្នាលជាងនៅស្រុក   ព្រោះនៅស្រុកនៅតាំងពីតូច   ចេញម៉ោតាំងពីតូច ដូច្នេះអត់ទាន់ដឹងអីទេដ៏ម៉ោនៅនេះយើងពេញដឹងក្តីយើងដឹងសុខដឹងទុក្ខថាមិនស្រួលទេដូចថាមាន អារម្មណ៍ដូចថាយើងទៅនោះយើងអត់ចេះនៅដែរ    ព្រោះយើងធ្លាប់នៅនេះយូរតាំងពីយើង ចេះដឹងគិតគូរនៅនេះ    បើលកាលនៅយើងមិនទាន់ចេះដឹងគិតគូរអីដងហ្នឹងខ្ញុំនេះមិនទាន់ចេះដឹង គិតគូរអីទេកុំតែចូលហ្នឹងបើម៉ែឪខ្ញុំនាំចូលក៏ខ្ញុំមិនចូល  អត់ដឹងចូលទេ

ដានី ៖ ចូលអីគេ?

គុំ ៖ ចូលបដិវត្តន៍ហ្នឹង  ម៉ែឪខ្ញុំចូលបានខ្ញុំចូលម៉ោហ្នឹង

ដានី ៖ ចុះកាលហ្នឹងឪពុកម្តាយមីងគាត់ចូលមកធ្វើបដិវត្តន៍?

គុំ ៖ ចា៎!គាត់ចូលធ្វើបដិវត្តន៍ហ្នឹងគាត់ចូលម៉ោតាមម៉ែឪទៅ  ដ៏ម៉ោនៅជាមួយគាត់មិនបានមួយឆ្នាំផង

ចុះធម្មតាគេឲ្យបែកហើយគេមិនឲ្យនៅជាមួយគ្នាម៉ែឪកូនទេ

ដានី ៖ ឆ្នាំ៧៣ហ្នឹង?

គុំ ៖ ចា៎!៧៣-៧៤ហ្នឹងខ្ញុំបែកមកនៅខាងដែលគេហៅ៨៧០

ដានី ៖ ម៉ោ៨៧០នៅម្តុំណាទៅ?

គុំ ៖ នៅខាងបម្លែ នៅខាងស្រុកនោះដែរតែគ្រាន់តែអគ្គភាពវាខុសគ្នា គេហៅមជ្ឈិមនោះ អគ្គភាពមជ្ឈិមនោះ កាលមុនខ្ញុំនៅស្រុកជាមួយម៉ែឪខ្ញុំដល់គេនេះគេរើសយកមកមជ្ឈិម

ដានី ៖ មជ្ឈិមនៅណា?

គុំ ៖ នៅជិតស្រុកហ្នឹងដែរ ប៉ុនគ្រាន់តែវាឆ្ងាយពីគ្នាប្រហែលពីនេះទៅខ្លាងរាប់អី

ដានី ៖ នៅជិតសន្ទុកហ្នឹងដែរ?

គុំ ៖ អត់ទេម៉ោនេះម៉ោជិតកំពង់ចាមហើយ

ដានី ៖ នៅខាងកំពង់ចាមវិញ?

គុំ ៖ ចា៎!

ដានី ៖ ខាងណាវិញ?

គុំ ៖ មាំជួរបម្លែមាំជួរអីហ្នឹង

ដានី ៖ នៅលើភ្នំ?

គុំ ៖ អត់ទេនៅព្រៃកៅស៊ូចំការកៅស៊ូអីហ្នឹង

ដានី ៖ អ៊ូនៅចំការកៅនៅខាងស្ទិចខាងស្នួចអីហ្នឹង?

គុំ ៖ ចា៎!គេហៅបម្លែ កាលហ្នឹងកន្លែងហ្នឹងគេហៅគីឡូ១៣-គីឡូ១៤ម៉េចទេ បម្លែហ្នឹងគេហៅភូមិបិទផ្លូវ ស្គាល់ទេភូមិបិទផ្លូវហ្នឹង?

ដានី ៖ ស្គាល់

គុំ ៖ ភូមិបិទផ្លូវហ្នឹងនៅតាមមាត់អូរ

ដានី ៖ បម្លែហ្នឹងសាខារបស់៨៧០ ៨៧០នៅហ្នឹងដែរ?

គុំ ៖ ចា៎! ៨៧០គេត្រឹមបង្កើតក្រោយកាលសម័យ៣ឆ្នាំទេ កាលមុនគេហៅមជ្ឈិម

ដានី ៖ ពីណាគេអ្នកគ្រប់គ្រងនៅហ្នឹង?

គុំ ៖ អ្នកដឹកនាំនៅប្រធានមន្ទីរកាលហ្នឹងខ្ញុំមិនសូវស្គាល់ដែរខ្ញុំនៅតូចៗ

ដានី ៖ កាលហ្នឹងមីងអាយុប៉ុន្មាន?

គុំ ៖ កាលហ្នឹងខ្ញុំអាយុ១៣-១៤ អ្នកនាំមានពូហុង ពូអីហ្នឹងកាលហ្នឹងនៅហ្នឹង

ដានី ៖ ពូហុងដែរ?

គុំៈ ចាំ!

ដានី ៖ អញ្ចឹងមីងស្គាល់ពូហុងយូរហើយ?

គុំ ៖ ចាំ!ស្គាល់គាំងពីឆ្នាំ៧៣-៧៤ មានពូចៀមអីស្គាល់គាំងយូរហើយ

ដានី ៖ គាត់អ្នកស្រុកអ្នកភូមិធម្មតាទេ?

គុំ ៖ អត់ទេ គាត់មិនដឹងនៅណាទេខ្ញុំអត់ដឹងដែរ តែគាត់ម៉ោតស៊ូនៅហ្នឹង

ដានី ៖ ចុះ ធុច អើ កុយ ធួន?

គុំ ៖ អត់ស្គាល់ដែរ ហ្នឹងគាត់នៅខាងបូព៌ាខ្ញុំអត់ស្គាល់គាត់

ដានី ៖ អត់ទេគាត់ខាង៣០៤

គុំ ៖ អញ្ចឹងខ្ញុំអត់ស្គាល់ដែរ ព្រោះនៅអង្គភាពខុសៗគ្នា

ដានី ៖ ចុះពេលបែក៧៥?

គុំ ៖ បែក៧៥ខ្ញុំមកនៅកាលបែក៧៥មុនដំបូងខ្ញុំមកនៅបម្ដែដល់ពេលចេញពីបម្ដែម៉ោមកនៅភ្នំពេញ ហ្នឹងនៅកន្លែងបុរីកីឡា នៅកន្លែងមកនៅមុនដំបូងគេហៅសាលាបច្ចេកទេសនៅជិតរទេសភ្លើង សាលាបច្ចេកទេសសូវៀតហ្នឹងមកនៅហ្នឹងគេនៅបើកវគ្គនៅហ្នឹង ពួកខ្ញុំអ្នកដាំបាយដាំអីបណ្ដាវគ្គ នៅហ្នឹង ដល់៧៦បានទៅនៅបុរីកីឡា

ដានី ៖ បុរីកីឡាគេហៅកន្លែងអីគេ?

គុំ ៖ ដែងមន្ទីរ?

ដានី ៖ បាទ!

គុំ ៖ គេហៅមន្ទីរក-៦ កាលពីនៅសាលាបច្ចេកទេសសូវៀតនេះគេហៅមន្ទីរក-៥ ឆ្នាំ៧៦ទៅនៅ ក-៦ហ្នឹងគេមន្ទីរពួកក-៦ហ្នឹងនៅបុរីកីឡា

ដានី ៖ គេឲ្យធ្វើទៅនៅហ្នឹង?

គុំ ៖ សម្រាប់បំរើភ្ញៀវម៉ោរៀនម៉ោអីហ្នឹងមកបើកវគ្គរៀន

ដានី ៖ ភ្ញៀវមកបើកវគ្គរៀនមកពីតាមស្រុក?

គុំ ៖ តាមស្រុក តាមឃុំ តាមភូមិភាគ ម៉ោរៀននៅហ្នឹង

ដានី ៖ កាលហ្នឹងភ្ញៀវរបស់មន្ទីរ៨៧០ឬក៏របស់ក្រសួងការបរទេស?

គុំ ៖ របស់មន្ទីរ៨៧០ អត់មិនរបស់ក្រសួងការបរទេសទេ

ដានី ៖ អញ្ចឹងមីងអ្នកនៅមន្ទីរ៨៧០មែននៅខាងក្រសួងការបរទេសទេ?

គុំ ៖ ចាំ!អ្នកដឹកនាំនៅហ្នឹងកាលហ្នឹងតាភូមិ អ្នកដឹកនាំនៅក-៥ ក-៦

ដានី ៖ ពីណាគេប្រធាន៨៧០?

គុំ ៖ ប្រធាន៨៧០ខ្ញុំមិនដឹងដែរ ខ្ញុំដឹងតែអ្នកដឹកនាំនៅក្នុងមន្ទីរៗខ្ញុំអត់ដឹងដែរ

ដានី ៖ ចុះមីងអត់ដែលទៅមន្ទីរ៨៧០ទេ?

គុំ ៖ អត់

ដានី ៖ មន្ទីរ៨៧០នៅម្តុំណា?

គុំ ៖ ខ្ញុំអត់ដឹងនៅត្រង់ណាផងគ្រាន់តែគេហៅក្រសួង ដូចជាក្រសួងការបរទេស ក្រសួង៨៧០អញ្ចឹង ខ្ញុំអត់ដឹងដែរ ខាងក្រសួងការបរទេសគឺខាងទទួលភ្ញៀវបរទេសហើយខាងខ្ញុំ៨៧០នេះ ខាងទទួលភ្ញៀងខាងក្នុងស្រុកយើង ខាងបើកវគ្គរៀនសូត្រអីហ្នឹង ពេលបើកវគ្គរៀនសូត្រអ៊ីៗអីទៅរៀននៅហ្នឹង

ដានី ៖ អ៊ីហ្នឹងអ៊ីណាខ្លះ?

គុំ ៖ អ៊ី ខៀវ សំផន អ៊ី នួន ជា អីហ្នឹង

ដានី ៖ អ៊ី ខៀវ សំផន អ៊ី នួន ជា អ៊ី អៀង សារីដែរ?

គុំ ៖ អ៊ី អៀង សារី គាត់មិនសូវទៅទេព្រោះគាត់ខាងក្រសួងការបរទេស ទៅតែអ៊ី ខៀវ សំផន អ៊ី នួន ជា តែប៉ុណ្ណឹងតែខាងបើកវគ្គបង្រៀនហ្នឹង

ដានី ៖ ចុះ ប៉ុល ពត ?

គុំ ៖ ប៉ុល ពត គាត់ទៅម្តងៗ ដូចជាពេលយកដូចជាប្រធានភូមិភាគអីទៅរៀនហ្នឹងបានគាត់ទៅ

ដានី ៖ ចុះមីងនៅបុរីកីឡាហ្នឹងយូរដែរ?

គុំ ៖ ខ្ញុំនៅតាំងពី៧៦រហូតបែក៧មករា ៧៩

ដានី ៖ ចុះកាលហ្នឹងមីងធ្លាប់មកលេងផ្ទះទេ?

គុំ ៖ អត់ៗដែលបានទៅលេងផ្ទះទេ កាលហ្នឹងទាល់តែគេប្រុងថា ៧៩ហ្នឹងគេប្រុងបើកឲ្យទៅលេងផ្ទះ ដូរគ្នាទៅលេងផ្ទះដូចជាម្តងម្នាក់ៗ មួយខែម្នាក់ឬក៏កន្លះខែម្នាក់ឬមាំអាទិត្យម្នាក់អញ្ចឹងទៅ ដល់ទទួលអញ្ចឹងទៅមានសង្គ្រាមអញ្ចឹងអត់បានទៅលេងរហូត

ដានី ៖ បែកផ្ទះយូររហូតដល់ឆ្នាំ៩០ជាងហើយបានឪពុកមីងមកលេង?

គុំ ៖ ចាំ!បែកយូរហើយ ម្តាយឪពុកខ្ញុំបែកតាំងពី៧៣

ដានី ៖ ចុះកាលហ្នឹងមីងពុថា ពេលបែក៧៣រហូតដល់៩០ជាងបានឪពុកមីងមកលេងអញ្ចឹង យ៉ាំងម៉េចដែរអារម្មណ៍មីងបានជួបឪពុកលើកដំបូង?

គុំ ៖ នឹក

ដានី ៖ ជួបគ្នាដំបូង?

គុំ ៖ ជួបគ្នាដំបូងយំ អរពេកយំ

ដានី ៖ គាត់មករកមីងឃើញ?

គុំ ៖ មុនដឹបូងសំបុត្រទាក់ទង មានអ្នកទៅស្រុកអញ្ចឹងគាត់ផ្ញើររូបថតតាមគេអញ្ចឹងម៉ោ គាត់ដូចថា ដឹងដំណឹងឃើងតែមិនច្បាស់ ចាស់ដល់ហើយទៅ អ្ហ្វ!កាលហ្នឹងមុនដំបូងខ្ញុំទេអ្នកផ្ញើររូបថតទៅ ស្រុកដូចគេដូចទ័ពអីគេទៅស្រុកផ្ញើររូបថតទៅស្រុកក៏ទៅគាត់ឃើញ គាត់ឃើញគាត់ផ្ញើរម៉ោ តាមរយៈអ្នកម៉ោអញ្ចឹងទៅ ទាក់ទងទៅម៉ោៗគាត់ដឹងគាត់មកលេង

ដានី ៖ ចុះឪពុកមីងគាត់ចូលធ្វើបដិវត្តន៍តាំងពីឆ្នាំណា?

គុំ ៖ គាត់ចូល៧៣

ដានី ៖ ហើយគាត់នៅ?

គុំ ៖ គាត់ចូលម៉ោគាត់នៅមន្ទីរស្រុក

ដានី ៖ មន្ទីរស្រុកនៅណាទៅ?

គុំ ៖ មន្ទីរស្រុក៨៣០នៅបិទថ្នូរហ្នឹង

ដានី ៖ គាត់នៅហ្នឹងរហូតឬគាត់មានផ្លាស់ទៅណាទៀត?

គុំ ៖ ខ្ញុំអត់ដឹងដែរខ្ញុំចេញពីគាត់តាំងចុង៧៣នោះ

ដានី ៖ គាត់អត់មាននិយាយប្រាប់ទេ?

គុំ ៖ គាត់ប្រាប់ដែរតែខ្ញុំអត់ចាំខ្ញុំភ្លេច គាត់ផ្លាស់ទៅនេះផ្លាស់ទៅនោះដែរតែខ្ញុំភ្លេច

ដានី ៖ ចុះមីងកាលពីជំនាន់៣ឆ្នាំឬក៏ក្រោយពេលហ្នឹងមីងធ្លាប់ជួយពីណាពេលគេមានទុក្ខឬក៏យ៉ាងម៉េច មីងមានធ្លាប់ជួយគេឬអត់?

គុំ ៖ ជួយតែពេលអ្នកដែលរត់ទៅជាមួយគ្នាឈឺ ចេះមើលគ្នាទៅ?

ដានី ៖ មើលយ៉ាងម៉េចទៅ?

គុំ ៖ មើលដូចថាឈឺ បបរឲ្យហូប រកថ្នាំរកអីឲ្យហូប វាមួនម្នាក់ជួនកាលខ្ញុំឈឺគេមើលគេថែដូចបង ប្អូនអញ្ចឹងតែតាមពិតគ្រាន់តែអ្នកនៅជាមួយគ្នា

ដានី ៖ ចុះមីងដូចថា ក្មេងៗដើរតាមផ្លូវឃើងដើរទៅជួប?

គុំ ៖ ជួប ខ្ញុំដើរទៅជួបតែអត់បានជួយគេ កាលហ្នឹងយោងតែព្រះអាត្មាឯងមិនចង់រួចទេ ហើយក្មេង ហ្នឹងកាលហ្នឹងក្មេងនឹងតូចដែរ វាចេះនិយាយចេះអីអស់ហើយហ្នឹង សួរថាអាអូននៅធ្វើអីទៀត វាថាបងអើយទៅៗខ្ញុំទៅមិនរួចទេ ខ្ញុំថាមោះទៅជាមួយបង វាថាអត់ទេខ្ញុំទៅមិនរួចទេ ខ្ញុំថាធ្វើ ម៉េចអញ្ចឹងបើខ្ញុំនៅឃើងស្លាប់ទាំងអស់គ្នា ទេបងឯងទៅៗ ដឹម៉ោពួៗម៉ោតាមក្រោយគាត់មាន កំលាំងគាត់លើកជិះកម៉ោដឹម៉ោទៅជួបបងប្អូនគេឲ្យគេទៅ ហើយមួយទៀតក្មេងប្រុសអាយុ ប្រហែលជា៤ឆ្នាំមិនដឹងទេពួៗហ្នឹងយកម៉ោៗនៅជាមួយពួកខ្ញុំទៅ ម៉ោនៅចិញ្ចឹមយូរម៉ោនៅ

ដែលខ្ញុំថាមកនៅត្រាងហ្នឹងដែលចេញពីដីថៃម៉ោរើសយកម៉ោពីណាទេពូៗទ័ពយកម៉ោមកនៅជាមួយពួកខ្ញុំ ហើយចេះទៀតក្មេងហ្នឹងពេលហូបបាយហ្នឹង ចុះកាលយើងគ្មានស្លាបព្រាអីពីណាវាចេះទៅរាវសំបកគ្រុបយកមកដួសបាយហូប ចុះរបស់តិចតួចយើងឲ្យវាហូបមុនហើយ ហើយវាថាអត់ទេហូបទាំងអស់គ្នាចេះទៀត ដល់នៅជាមួយបានកន្លះខែគេម៉ោគេថាបងប្អូនគេៗយកឲ្យគេទៅ យើងឲ្យគេទៅមិនដឹងធ្វើម៉េចបើគេថាបងប្អូនគេ សួរគេម្ចាស់ខ្លួនដែរ ម្ចាស់ខ្លួនអត់ចង់ទៅទេចង់នៅជាមួយពួកខ្ញុំស្រួល ហើយគេថាបងប្អូនគេមិនដឹងបងប្អូនគេពិតឬ យ៉ាងណាអត់ដឹងដែរ

ដានី ៖ ចុះមីងតាមផ្លូវធ្វើដំណើរមីងមានដែលឲ្យអង្ករ ឲ្យអីគេដែរឬអត់?

គុំ ៖ ដែលតាមផ្លូវម៉ោអត់ដែលមានឲ្យអីគ្នាទេ តែបើថាជួបគ្នាថាអត់អញ្ចឹងចែកគ្នាទៅខ្លះទៅណា មិនដាច់ខាតថាអត់សុទ្ធទេ ម៉ោម្នាក់ៗអត់មានថាអ្នកណាម្នាក់ៗថាអត់ទេសុទ្ធតែម្ចាស់ការរៀងៗខ្លួនខ្លាចតែងាប់រៀងខ្លួនអត់ហានហូបអស់ទេទោះបីមានអង្ករទាំងខែៗយ៉ាងណាក៏អត់ហានហូបអស់ដែរ សុខចិត្តនាំគ្នាបបរហូបលាយជាមួយកូនផ្តៅ កូនអី

ដានី ៖ ចុះអ្នកស្រុកអ្នកភូមិមីងធ្លាប់នៅកាលពីមុនមីងមានដែលជួបពួកគាត់ទេ?

គុំ ៖ អ្នកស្រុកអ្នកភូមិខ្លះធ្លាប់ជួបគាត់ដែរពេលគាត់មកលេងជួប

ដានី ៖ បើអ្នកនៅនោះអ្នកអត់ដែលមកលេងអត់បានជួប?

គុំ ៖ អត់ដែលបានជួបទេ ប្អូន ញាតិអីហ្នឹងម៉ោបានជួប អ្នកអត់ម៉ោអត់បានជួបដែរ

ដានី ៖ ចុះមីងគិតបំណងថាឆ្នាំណាដែលទៅលេងស្រុក?

គុំ ៖ ខ្ញុំដូចកំណត់មិនបានទេ ខ្ញុំថាឲ្យតែមានឆ្នាំណាក៏ទៅដែលឲ្យតែមានលុយ តែមិនដឹងរកអីឲ្យបានលុយធំដុំទៅបើធ្វើចំការរវល់តែខូចដែរ

ដានី ៖ ចុះមីងឥឡូវមីងមានដែលលឺពត៌មានអីទាក់ទងរឿងតុលាការ គេបង្កើតការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

គុំ ៖ បានលឺដែរឃើញមើលដែរហ្នឹង

ដានី ៖ តើយល់តុលាការហ្នឹងគេបង្កើតត្រឹមត្រូវឬក៏មិនត្រឹមត្រូវ?

គុំ ៖ ត្រឹមត្រូវហើយព្រោះអីកាត់ទោសអ្នក ដើម្បីវែកញែកឲ្យឃើញអ្នកខុសអ្នកត្រូវ

ដានី ៖ ខ្ញុំគិតថាត្រឹមត្រូវដែលអញ្ចឹង ចុះមីងដឹងថាដូចថាខ្ញុំប្រាប់មិញមានអ៊ីៗដែលដូចជាអ៊ី ខៀវ សំផន អ៊ី អៀង សារី អ៊ី នួន ជា ឥឡូវត្រូវតុលាការគេកាត់ទោសហ្នឹងមីងគិតម៉េច ដែរអញ្ចឹង?

គុំ ៖ ខ្ញុំគិតថា កាត់ទោសគាត់បើថាបានកាត់ទោសគាត់ហើយ គាត់បាននិយាយវែកញែកពីរឿងខុស

ត្រូវហ្នឹងបានត្រឹមត្រូវ បើគាត់អត់បានវែកញែកឲ្យបានត្រឹមត្រូវហ្នឹងខ្ញុំថាអត់ត្រឹមត្រូវ ព្រោះអីកំហុសហ្នឹងគាត់ក៏មានកំហុសគេក៏មានកំហុស កំហុសដូចគ្នាវាមែនកំហុសតែគាត់ តាមខ្ញុំដឹងគាត់ដឹកនាំពួកខ្ញុំម៉ោគាត់មិនដែលប្រាប់ថាធ្វើឲ្យខូចបេះចុះៗអត់ នឹងជាចំពោះខ្លួនខ្ញុំដែលធ្លាប់នៅជិតគាត់ហ្នឹង ធ្លាប់តែគាត់ណែនាំឲ្យធ្វើអីឲ្យល្អចំរើនដល់ជាតិគាត់គិតតែនិយាយតែប៉ុណ្ណឹង ហើយដល់រឿងអីផ្សេងៗទៀតខ្ញុំអត់ដឹងដែរ រឿងប្រល័យពូជសាសន៍រឿតអីអាហ្នឹងខ្ញុំអត់ដឹងដែល ព្រោះអីណែនាំឲ្យធ្វើតែល្អធ្វើម៉េចឲ្យតែល្អ ហើយពួកខ្ញុំនៅភ្នំពេញហ្នឹងគាត់ណែនាំមានតែថា ឲ្យហូបបាយបេះសន្សំថៃ កុំហូបខ្ជីខ្ជាយដើម្បីទុកជូនប្រជាជននៅតាមសហករណ៍ គេខំធ្វើស្រែធ្វើចំការបញ្ជូនឲ្យយើងនៅទីក្រុងហ្នឹង គាត់មានតែថាបញ្ជោរឲ្យយើងខំធ្វើបេះធ្វើចុះម៉េច ដូចអត់មានគាត់មានណែនាំអីអាក្រក់ទេ អញ្ចឹងបានថាទាល់តែវែកញែកគាត់បាននិយាយខ្លួនគាត់ថាបេះចុះបេះមួយៗហ្នឹងបានត្រឹមត្រូវ ។

ដានី ៖ ចុះមីងមានធ្លាប់អញ្ជើញទៅភ្នំពេញទៅមើលគុកទួលស្លែងដែរឬអត់?

គុំ ៖ អត់ខ្ញុំអត់ដែលបានទៅទេ

ដានី ៖ ចុះកាលមីងនៅពេញមីងដឹងថាមានគុកទួលស្លែងហ្នឹងអត់?

គុំ ៖ ខ្ញុំដឹងតែដឹងអត់ច្បាស់ ខ្ញុំដឹងតែថាដូចថាមានកំហុសអីអញ្ចឹងគេយកទៅលត់ដំខ្ញុំដឹងតែប៉ុណ្ណឹង ដូចខាងជាប់ខ្សែរយៈខាងហ្នឹងគេចាប់ដូចចាប់ខាងគណៈភូមិភាគបូព៌ាអញ្ចឹងគេយកអ្នកពាក់ពន្ធ័នឹងទៅលត់ដំ

ដានី ៖ ចុះគាត់មកវិញអត់អ្នកទៅលត់ដំហ្នឹង?

គុំ ៖ អ្នកលត់ដំហ្នឹងដល់តែរត់យូរជួបគ្នាដែរ

ដានី ៖ ចុះកាលជំនាន់ហ្នឹងមានប្រជាជនស្លាប់ច្រើនគឺពាក់កណ្តាលឆ្នាំណា?

គុំ ៖ ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែពេលខ្ញុំរត់ ពេលរត់ៗម៉ោពីភ្នំពេញម៉ោនៅកំពង់ឆ្នាំង គេហៅតំបន់៣១ខ្ញុំដឹងតាមរយៈប្រជានទេ ខ្ញុំសួរគាត់ថាហីចុះគេដឹកយើងយកទៅណា ហើយគាត់ថាគេដឹកយកទៅសម្លាប់ចោល ខ្ញុំនឹកឃើញថាហីចុះម៉េចបានអញ្ចឹង ខ្ញុំថាអញ្ចឹងរឿងហ្នឹងវាពិបាកដែររកថាមិនត្រូវដល់ពេលរត់គ្នាអ្នករត់រួចម៉ោ ម៉ោជាមួយពួកខ្ញុំអីម៉ោជាមួយតែគ្នាហ្នឹង ដូចថាគេយកទៅសម្លាប់ចោលលួចរត់រួចអញ្ចឹង រត់ម៉ោតស៊ូដូចគ្នា

ដានី ៖ ចុះមីងកាលហ្នឹងហេតុអីបានមីងរត់នៅពេលកាលយួនចូលម៉ោ?

គុំ ៖ ចុះបើមិនរត់កាលហ្នឹងខ្ញុំខ្លាច

ដានី ៖ ខ្លាចអី?

គុំ ៖ ខ្លាចយួន

ដានី ៖ ហេតុអីបានមីងខ្លាចយួនកាលហ្នឹង?

គុំ ៖ ចុះកាលហ្នឹងខ្ញុំនៅហ្នឹងដឹងថាកាលហ្នឹងគេវ៉ៃយួនទៅខាងបូព៌ា ដល់ពេលយួនបុកម៉ោមិនខ្លាចមិនរត់

ដានី ៖ ប៉ុន្តែមានគេប្រាប់ថាម៉េចៗឬអត់?

គុំ ៖ អត់មានទេ មានតែកាលមុនគេណែនាំពីការការពារទឹកដីខ្មែរ យួនចូល

ដានី ៖ អ្នកណាគេដែលណែនាំឲ្យការពារទឹកដីហ្នឹង?

គុំ ៖ ខាងអង្គការដូចជាអឺៗអ្នកដឹកនាំ

ដានី ៖ គាត់អត់មានប្រាប់ថាបើសិនជាយើងអត់ធ្វើតាមអញ្ចឹងទេយួនចាប់អារក?

គុំ ៖ អត់ៗលឺថាអញ្ចឹង ប៉ុនចុះបើគេម៉ោអស់ហើយយើងនៅជាមួយអ្នកណា រត់អស់ហើយនៅមន្ទីររត់ម៉ោអស់ហើយតែអ្នកនៅរត់ម៉ោក្រោយរួចអត់អីដែរ លឺគេប្រកាសថាបើបងប្អូននៅហ្នឹងអីគេឲ្យចេញម៉ោ ប៉ុនម៉េចទុកចិត្ត អត់ទុកចិត្តទេរត់ម៉ោទាល់តែរួច

ដានី ៖ ចុះពេលដែលមីងម៉ោដល់ដូចថាម៉ោដល់ខាងក្តាម ដល់ខាងរលៀម មកដល់ភូមិដូងនេះហើយកាលហ្នឹងនៅតែខ្លាចយួនអញ្ចឹង

គុំ ៖ នៅតែខ្លាច

ដានី ៖ ខ្លាចដល់ពេលណាទៅ?

គុំ ៖ ខ្លាចម៉ោរហូត

ដានី ៖ ឥឡូវនៅតែខ្លាច

គុំ ៖ ឥឡូវធម្មតា

ដានី ៖ ដល់ពេលសមាហរន្តកម្មហើយ យើងធ្វើម៉េចទៅដូចថាកាលពីមុនសមាហរន្តកម្មនឹងក្រោយសមាហរន្តកម្មហើយដូចថាដឹងរឿងរ៉ាវនៅក្នុងផ្ទះហ្នឹងខុសគ្នាម៉េចទៅ?

គុំ ៖ ខុសគ្នារកថាមិនត្រូវ

ដានី ៖ បាទ!ខ្ញុំអរគុណមីងច្រើនដែលបានផ្តល់ពត៌មានដែលទាក់ទងពីជីវិតរបស់មីងតាំងពីដើមម៉ោរហូតល់ចប់ ។

គុំ ៖ ចា៎!

«ចប់»